ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
អគ្គនាយកដ្ឋានរដ្ឋបាល

លេខ : ០១ រដក/អករដ

ថ្ងៃ ... ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ,ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២០

នាយកដ្ឋានបណ្តុះបណ្តាល
ចូល
លេខ 64 ម៉ោង 3.30
ថ្ងៃទី 13 - 2 - 20
ផ្ញើ

# របាយការណ៍
## ស្តីពី
## សកម្មភាព និងលទ្ធផលការងារប្រចាំខែមករា ឆ្នាំ២០២០ និងទិសដៅបន្តសម្រាប់ខែកុម្ភៈ ឆ្នាំ២០២០ របស់អគ្គនាយកដ្ឋានរដ្ឋបាល

អគ្គនាយកដ្ឋានរដ្ឋបាល គឺជាអង្គភាពមួយក្នុងចំណោមអង្គភាពទាំង១១ ចំណុះក្រសួងមហាផ្ទៃ មានតួនាទីជាសេនាធិការឱ្យក្រសួង ក្នុងការអនុវត្តច្បាប់រៀបចំអង្គការ ពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៦ នៃរដ្ឋសភា ព្រមទាំងសម្របសម្រួលក្នុងការបង្កើត ការចុះបញ្ជី និងគ្រប់គ្រងសកម្មភាពសមាគម អង្គការមិនមែនរដ្ឋាភិបាល និងគណបក្សនយោបាយ។

ក្នុងខែមករា ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានអនុវត្តការងារតាមតួនាទី ភារកិច្ច ដោយសម្រេចលទ្ធផលបានដូចខាងក្រោម៖

### I-សកម្មភាពការងារ និងលទ្ធផល

#### ១-ការងារលិខិតស្នាម និងឯកសារផ្សេងៗ

-បានទទួលលិខិត និងឯកសារ ដែលបញ្ជូនមក ពីអគ្គលេខាធិការដ្ឋាន និងអង្គភាពនានាចំណុះ ក្រសួងមហាផ្ទៃ សរុបចំនួន ៨១០ច្បាប់ និងបានធ្វើការបែងចែកជូនទៅនាយកដ្ឋានចំណុះរួមមាន៖ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ២៦៥ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ៤៩ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ២៤៩ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ៤១ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ៦០ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ១៤៦ច្បាប់។

-បានទទួលលិខិតមកពីនាយកដ្ឋានជំនាញចំណុះអគ្គនាយកដ្ឋានរដ្ឋបាលមានចំនួន ៤៨២ច្បាប់ ដែលក្នុងនោះ មកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ១៨៧ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ១៥ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ១៣៤ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ៣៥ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ៣៤ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៧៧ច្បាប់ ដើម្បីដាក់ជូនអគ្គនាយកជ្រាបជារបាយការណ៍ និងពិនិត្យសម្រេច។

-បានចាត់ចែងបញ្ជូនឯកសារចំនួន ៣៣៥ច្បាប់ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងជ្រាបជារបាយការណ៍និងពិនិត្យ សម្រេច ដែលក្នុងនោះឯកសារមកពីនាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ១៣០ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ០៥ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ១១៥ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ២៨ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ២០ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ៥០ច្បាប់។

-បានទទួលឯកសារចំនួន២០៣ច្បាប់ ដែលថ្នាក់ដឹកនាំក្រសួងមហាផ្ទៃពិនិត្យ សម្រេចរួច និងបញ្ជូនទៅនាយកដ្ឋានចំណុះ ដើម្បីចាត់ចែងបន្តរួមមាន៖ នាយកដ្ឋានកិច្ចការរដ្ឋបាលរាជធានី ខណ្ឌ និងខេត្តចំនួន ៥៨ច្បាប់ នាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ចំនួន ០៥ច្បាប់ នាយកដ្ឋានបុគ្គលិកចំនួន ៧៥ច្បាប់ នាយកដ្ឋានបណ្តុះបណ្តាលចំនួន ២៥ច្បាប់ នាយកដ្ឋានមុខងារ និងធនធានចំនួន ១៧ច្បាប់ និងនាយកដ្ឋានកិច្ចការសមាគម និងគណបក្សនយោបាយចំនួន ២៣ច្បាប់។

**២-ការចារចេញលិខិតបង្គាប់ការ និង លិខិតបញ្ជាបេសកកម្ម**

ក្នុងខែមករាឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានចេញលិខិតបង្គាប់ការ និងលិខិតបញ្ជាបេសកកម្មសរុបចំនួន ៦៧ច្បាប់ ក្នុងនោះ លិខិតបង្គាប់ការចំនួន ៣០ច្បាប់ និងលិខិតបញ្ជាបេសកកម្មចំនួន ៣៧ច្បាប់ ជូនថ្នាក់ដឹកនាំ និងមន្ត្រីចំណុះអគ្គនាយកដ្ឋានរដ្ឋបាល ដើម្បីចុះទៅបំពេញបេសកកម្មនៅតាមបណ្តាខេត្តនានា។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានចុះទិដ្ឋាការជូនមន្ត្រីរាជការមកពីបណ្តាខេត្តដែលមកបំពេញបេសកកម្មនៅក្រសួងមហាផ្ទៃផងដែរ។

**៣-ការចារប្រជុំ និងសិក្ខាសាលាផ្សេងៗ**

ក្នុងខែមករាឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាល បានរៀបចំកិច្ចប្រជុំ និងចាត់មន្ត្រីចូលរួមកិច្ចប្រជុំ សិក្ខាសាលា វេទិកា និងកម្មវិធីនានាដូចខាងក្រោម៖

-ចូលរួមជាមួយ**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ក្នុងឱកាសអនុញ្ញាតឱ្យ៖

- ឯកឧត្តម **Kazuyuki NAKANE** សមាជិករដ្ឋសភា និងជាអតីតរដ្ឋលេខាធិការក្រសួងការបរទេសជប៉ុន ចូលជួបសម្តែងការគួរសម
- ឯកឧត្តម **Bjorn Haggmark** ឯកអគ្គរដ្ឋទូតទើបតែងតាំងថ្មី នៃប្រទេសស៊ុយអែត ចូលជួបសម្តែងការគួរសម
- ប្រតិភូក្រុមហ៊ុន **លីង ហាង អរយើត** ចូលជួបសម្តែងការគួរសម
- ប្រតិភូនៃសហភាពសហជីពសារព័ត៌មានកម្ពុជា ចូលជួបសម្តែងការគួរសម។

▪ ការប្រជុំ សិក្ខាសាលា៖

-រៀបចំកិច្ចប្រជុំពិភាក្សាលើកិច្ចការកែសម្រួលតួនាទី ភារកិច្ច រចនាសម្ព័ន្ធរបស់អគ្គនាយកដ្ឋានរដ្ឋបាល និងសាលាជាតិរដ្ឋបាលមូលដ្ឋាន

-រៀបចំកិច្ចប្រជុំក្រុមការងារអន្តរក្រសួង ដើម្បីពិភាក្សាលើសេចក្តីព្រាងកម្រងបញ្ជីសំណួរសម្រាប់ចុះសិក្សាលើទម្រង់បែបបទ និងនីតិវិធីក្នុងការផ្តល់សេវារបស់វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-ចូលរួមកិច្ចប្រជុំរៀបចំសេចក្តីព្រាងច្បាប់ វិសោធនកម្មច្បាប់ស្តីពីអន្តោប្រវេសន៍ និងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ

-ចូលរួមកិច្ចប្រជុំអនុគណៈកម្មការឯកសារបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ និងឯកសារពាក់ព័ន្ធការងារសន្និបាតរបស់ក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំពិនិត្យពិភាក្សាសំណើ និងអនុសាសន៍របស់អង្គការសង្គមស៊ីវិល ក្នុងការធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-ចូលរួមកិច្ចប្រជុំផ្លូវរបាយការណ៍បូកសរុបលទ្ធផលប្រឡងប្រណាំងអនុវត្តគោលនយោបាយ "ភូមិ ឃុំមានសុវត្ថិភាព" ប្រចាំឆ្នាំ២០១៩

-ចូលរួមកិច្ចប្រជុំពិនិត្យពិភាក្សាលើសំណើធ្វើសមាហរណកម្មបុគ្គលិក និងរៀបចំមុខតំណែងគ្រប់គ្រងតាមការិយាល័យ និងអង្គភាពនានារបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ ដែលរៀបចំឡើងដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គ.ជ.អ.ប

-ចូលរួមកិច្ចប្រជុំពិភាក្សាការកំណត់តំបន់ជួបការលំបាក និងតំបន់ដាច់ស្រយាលក្នុងវិស័យសុខាភិបាល ដែលរៀបចំឡើងដោយក្រសួងសុខាភិបាល

-ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ ស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រដើម្បីពង្រឹងសមត្ថភាពអង្គការសហគមន៍មូលដ្ឋានឱ្យមាននិរន្តរភាពរបស់អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

-ចូលរួមកិច្ចប្រជុំក្រុមការងារបច្ចេកទេសអន្តរក្រសួងប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មលើកទី១៥ នៅធនាគារជាតិ នៃកម្ពុជា

-ចូលរួមកិច្ចប្រជុំ ស្តីពីការរៀបចំនីតិវិធីនៃការផ្ទេរការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ

-ចូលរួមកិច្ចប្រជុំពិភាក្សាលើការរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីលក្ខខណ្ឌនិងនីតិវិធីហិរញ្ញវត្ថុសម្រាប់ការផ្ទេរធនធានហិរញ្ញវត្ថុមានភ្ជាប់លក្ខខណ្ឌទៅឱ្យរដ្ឋបាលរាជធានីខេត្ត ក្នុងការអនុវត្តមុខងារសេវាសុខាភិបាល

-ចូលរួមកិច្ចប្រជុំពិភាក្សា ស្តីពីនីតិវិធីចំណាយថវិកា និងការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ដែលមានលក្ខណៈស្តង់ដា

-ចូលរួមកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងគោលនយោបាយស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ២០១៩-២០២៨ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ២៣៨ អនក្រ.បក ចុះថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម

-ចូលរួមកិច្ចប្រជុំក្រុមការងាររៀបចំវគ្គតម្រង់ទិស សម្រាប់ក្រុមគោលដៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីពិភាក្សាលើផែនការសកម្មភាពបណ្តុះបណ្តាល និងសេចក្តីព្រាងបឋមមាតិកាឯកសារបណ្តុះបណ្តាល

-ចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការផ្តល់សេវាសាធារណៈលើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ(ដី-ផ្ទះ)នៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ចូលរួមកិច្ចប្រជុំក្រុមការងារ ស្តីពីច្រកទ្វារព្រំដែនគោកកម្ពុជា-វៀតណាម នៅរដ្ឋធានីហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

-ចូលរួមកិច្ចប្រជុំក្រុមការងារអន្តរក្រសួងរៀបចំ និងលើកទឹកចិត្តគម្រោងចំណតសាធារណៈ នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ចូលរួមកិច្ចប្រជុំការអនុវត្តគម្រោងសម្បទានដីសេដ្ឋកិច្ច នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ចូលរួមកិច្ចប្រជុំពិភាក្សាលើសំណើសុំកាត់ទីតាំងដីចំនួន ០២កន្លែង របស់រដ្ឋបាលខេត្តបាត់ដំបងចេញពីតំបន់ប្រើប្រាស់ច្រើនយ៉ាងសំឡូត ដើម្បីរៀបចំគម្រោងអភិវឌ្ឍន៍តំបន់ព្រំដែនកម្ពុជា-ថៃក្នុងភូមិសាស្ត្រធករកា ឃុំសំឡូត ស្រុកសំឡូត ខេត្តបាត់ដំបង

-ចូលរួមកិច្ចប្រជុំពិភាក្សាដោះស្រាយបញ្ហាប្រជាពលរដ្ឋផ្ញើសារចូល Facebook Page សម្តេចក្រឡាហោម ដែលប្រព្រឹត្តទៅ នៅទីស្តីការក្រសួងមហាផ្ទៃ

-ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយ និងអនុវត្តការងារក្នុងផែនការយុទ្ធសាស្ត្រស្តីពីការជំរុញភូមិមួយ ផលិតផលមួយ ៥ឆ្នាំ (២០១៩-២០២៣) នៅទីស្តីការគណៈរដ្ឋមន្ត្រី

-ចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការរៀបចំប្រព័ន្ធថ្មីសម្រាប់ការគ្រប់គ្រងសំរាម សំណល់រឹងនៅតាមបណ្តាខេត្តជាប់តំបន់ឆ្នេរ

-ចូលរួមសិក្ខាសាលា ចែករំលែកបទពិសោធន៍ បិទបញ្ចប់គម្រោងពង្រឹងសមត្ថភាពដល់បណ្តាញអ្នកនេសាទ និងសម្ព័ន្ធអង្គការក្រៅរដ្ឋាភិបាល ឆ្ពោះទៅរកភាពជាម្ចាស់ក្នុងការគ្រប់គ្រងធនធានជលផល ប្រកបដោយនិរន្តរភាពរបស់អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ស្តីពី ការរៀបចំសេចក្តីព្រាងផែនការយុទ្ធសាស្ត្រស្តីពីការកសាង និងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤ ឆ្នាំ២០២១-២០២៥ និងការផ្សព្វផ្សាយលទ្ធផលវាយតម្លៃតម្រូវការបណ្តុះបណ្តាល និងវិក្រឹត្យការឆ្នាំ២០២០

-ចូលរួមសិក្ខាសាលាផ្សព្វផ្សាយ " គោលនយោបាយជាតិស្តីពីវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២០-២០៣០" ដែលរៀបចំដោយក្រសួងផែនការ

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ ស្តីពីការបង្កើតក្រុមការងារឆ្លើយតបជាពហុវិស័យ ចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅថ្នាក់ក្រោមជាតិ(ហៅកាត់ថាក្រុមការងារអំពើហិង្សាទាក់ទងនឹងយេឌ័រ) ដែលរៀបចំដោយក្រសួងកិច្ចការនារី

-ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការអនុវត្តទោសនៅក្រៅឃុំ និងស្តារនីតិសម្បទាជនល្មើសដោយមានការចូលរួមពីសហគមន៍ នៅសណ្ឋាគារសោន់វ៉េភ្នំពេញ

-ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ត្រីភាគី ស្តីពីការធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ ដែលរៀបចំដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-ចូលរួមសិក្ខាសាលា ស្តីពីនីតិវិធី និងបែបបទ នៃការអនុវត្តចំណាយវិនិយោសាធារណៈ ហិរញ្ញប្បទានដោយថវិកាជាតិ (គម្រោងវិនិយោគផ្ទាល់) ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

▪ កម្មវិធីផ្សេងៗ៖

-ចូលរួមពិធីជួបជុំ រវាងសម្តេចតេជោនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងអ្នកសារព័ត៌មានក្នុងស្រុក លើកទី៤ នៅមជ្ឈមណ្ឌលកោះពេជ្រ

-ចូលរួមមហាសន្និបាតអាណត្តិទី៣នៃសម្ព័ន្ធភាពជាតិសមាគមក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ នៅសណ្ឋាគារភ្នំពេញ រាជធានីភ្នំពេញ

-ចូលរួមពិធីសម្ពោធដាក់ឱ្យដំណើរការជាផ្លូវការអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត នៅសាលាខេត្តពោធិ៍សាត់

-ចូលរួមកម្មវិធីបូកសរុបលទ្ធផលការងារសម្រេចបានឆ្នាំ២០១៩ និងទិសដៅឆ្នាំ២០២០ របស់បេឡាជាតិសន្តិសុខសង្គម នៅសណ្ឋាគារតារាអែរផត

-ចូលរួមវេទិកាកសិកម្ម រុក្ខាប្រមាញ់ នេសាទ និងសម្បទានដីសេដ្ឋកិច្ច នៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ៤-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត

### ៤.១-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុង

#### ៤.១.១-លិខិតបទដ្ឋានគតិយុត្តដែលសម្រេចបាន

សេចក្តីណែនាំលេខ ០០១សណន ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ ស្តីពីរបៀបរបបធ្វើការងាររបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ។

#### ៤.១.២-លិខិតបទដ្ឋានគតិយុត្តដែលកំពុងរៀបចំ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពី របបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈចំពោះក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសាលាជាតិរដ្ឋបាលមូលដ្ឋាន

-សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត ការលុបបោលភូមិ និងការកែសម្រួលព្រំប្រទល់របស់រដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋាន និងឯកសារពាក់ព័ន្ធ

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី នីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពី ការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងគំរូដីកាស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងវិស័យនានាទៅឱ្យរដ្ឋបាលខណ្ឌទាំងអស់ នៃរាជធានីភ្នំពេញ

-សេចក្តីព្រាងគំរូកិច្ចសន្យា ស្តីពីការផ្តល់សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាម សំណល់រឹងទីប្រជុំជនរបស់រដ្ឋបាលក្រុង ស្រុក

-សេចក្តីព្រាងសៀវភៅណែនាំស្តីពី "កិច្ចការរដ្ឋបាល" សម្រាប់ប្រើប្រាស់នៅតាមអង្គភាពនានា(ផ្នែករដ្ឋបាលស៊ីវិល) ចំណុះទីស្តីការក្រសួងមហាផ្ទៃ។

**៤.២-លិខិតបទដ្ឋានគតិយុត្តដែលសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ**

**៤.២.១-លិខិតបទដ្ឋានគតិយុត្តកំពុងសហការរៀបចំ**

-សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ

-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ

-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រង និងការបែងចែកចំណូល កម្រៃសេវារដ្ឋបាលនៃអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-សេចក្តីព្រាងអនុក្រឹត្យថ្មីស្តីពី ការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែននៅទូទាំងព្រះរាជាណាចក្រកម្ពុជា

-សេចក្តីព្រាងអនុក្រឹត្យស្តីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម០២ឆ្នាំ ក្នុងគ្រួសារក្រីក្រ

-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការកែសម្រួលអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពី ការប្រមូលចំណូលពីការលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង

-សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពី ការបែងចែកចំណូលពីថ្លៃលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រខេត្តបាត់ដំបង

-សេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាលរាជធានី ខេត្ត

-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៩-២០៣០។

**៥-ការងារបុគ្គលិក**

**៥.១-ការងារក្របខ័ណ្ឌ**

គិតត្រឹមខែមករាឆ្នាំ២០២០ ស្ថានភាពក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃសរុបមានចំនួន ១៣.៣៤០រូប/ស្រី៣.៤៤១រូប (ក្នុងនោះក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន ១.០០៥រូប/ស្រី២៤២រូប ក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលថ្នាក់ក្រោមជាតិចំនួន ៩.២០២រូប/ស្រី២.៧៣៤រូប ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ជាតិចំនួន ១.១៧៦រូប/ស្រី១៩០រូប ក្របខ័ណ្ឌមន្ត្រីពន្ធនាគារថ្នាក់ក្រោមជាតិចំនួន ១.៩៥៧រូប/ស្រី ២៧៥រូប) បើប្រៀបធៀបទៅនឹងខែធ្នូ ឆ្នាំ២០១៩ ក្របខ័ណ្ឌកើនឡើងចំនួន ១១រូប/ស្រី០២រូប។ ជាមួយគ្នានេះដែរ ក្រសួងមហាផ្ទៃ ក៏បានបញ្ចូលក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិលចំនួន ១៨រូប/ស្រី០២រូប។ ក្របខ័ណ្ឌចេញចំនួន ០៧រូប (ក្នុងនោះផ្ទេរទៅក្នុងក្របខ័ណ្ឌក្រសួងនានាចំនួន ០៦រូប លុបឈ្មោះដោយមរណៈភាពចំនួន ០១រូប។

### ៥.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល

ក្នុងខែមករា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានរៀបចំប្រកាសដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ចំនួន ០៦រូប និងបានរៀបចំព្រះរាជក្រឹត្យ និងប្រកាសដាក់មន្ត្រីពន្ធនាគារឱ្យចូលនិវត្តន៍ចំនួន ១៦រូប ។ ជាមួយគ្នានេះដែរ ក៏បានអនុញ្ញាតឱ្យមន្ត្រីរាជការឈប់សម្រាកពីការងារ និងចូលបម្រើការងារវិញសរុបចំនួន ១០រូប/ស្រី០១រូប(ក្នុងនោះ ឈប់សម្រាកលំហែមាតុភាពចំនួន ០៩រូប និងសុំចូលបម្រើការងារក្នុងអង្គភាពវិញបន្ទាប់ពីសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សចំនួន ០១រូប/ស្រី០១រូប)។ ទន្ទឹមនោះថ្នាក់ដឹកនាំក្រសួងក៏បានផ្តល់គ្រឿងឥស្សរិយយសតាមលំដាប់ថ្នាក់ជូនមន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិសរុបចំនួន ៣៩៩គ្រឿង ក្នុងនោះគ្រឿងឥស្សរិយយសជាតូបការចំនួន ០៣គ្រឿង គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជាតាមលំដាប់ថ្នាក់ចំនួន ៧៨គ្រឿងរួមមាន៖ (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៤គ្រឿង ថ្នាក់មហាសេនាចំនួន ១៤គ្រឿង ថ្នាក់ធិបឌិន្ទ ចំនួន ១១គ្រឿង ថ្នាក់សេនាចំនួន ៣៧គ្រឿង និងថ្នាក់អស្សឫទ្ធិចំនួន១២គ្រឿង) គ្រឿងឥស្សរិយយសមុនីសារាភ័ណ្ឌ ចំនួន ៦០គ្រឿងរួមមាន៖ (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០៣គ្រឿង ថ្នាក់មហាសេនាចំនួន ០២គ្រឿង ថ្នាក់ធិបឌិន្ទចំនួន ០៦គ្រឿង ថ្នាក់សេនាចំនួន ១៦គ្រឿង និងថ្នាក់អស្សឫទ្ធិចំនួន ៣៣គ្រឿង) និងមេដាយការងារតាមលំដាប់ថ្នាក់ចំនួន ២៥៨គ្រឿង រួមមាន៖(ថ្នាក់មាសចំនួន៦៤គ្រឿង ថ្នាក់ប្រាក់ចំនួន៦១គ្រឿង ថ្នាក់សំរឹទ្ធចំនួន១៣៣គ្រឿង)។ជាមួយគ្នានេះ ដែរក្រសួងមហាផ្ទៃក៏បានផ្តល់ប័ណ្ណសម្គាល់ខ្លួនដល់មន្ត្រីសម្រាប់ចេញ-ចូលក្រសួងចំនួន ៦១រូប/ស្រី១៨រូប។

### ៥.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ

ក្នុងខែមករា ឆ្នាំ២០២០ ស្ថានភាពបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិលតាមមុខតំណែង ដែលកំពុងបម្រើការងារនៅគ្រប់អគ្គនាយកដ្ឋាន និងអង្គភាពចំណុះក្រសួងមហាផ្ទៃសរុបចំនួន១.០០៥រូប/ស្រី២៤២រូប ស្មើនឹង ២៤.០៧% ដែលក្នុងនោះរួមមាន ៖

-មន្ត្រីរាជការស៊ីវិលចំនួន ៩៨៧រូប/ស្រី ២៤១រូប ស្មើនឹង ២៤,៤១% ក្នុងនោះរួមមាន (រដ្ឋលេខាធិការចំនួន ០៣រូប អនុរដ្ឋលេខាធិការចំនួន ០៤រូប/ស្រី០១រូប អគ្គនាយកចំនួន ០១រូប អគ្គនាយករងចំនួន ២៧រូប/ស្រី០២រូប អគ្គលេខាធិការរងចំនួន ០៤រូប/ស្រី០១រូប គណៈកម្មាធិការ គ.ជ.ប.ទ ចំនួន ០៣រូប (ក្នុងនោះសមាជិកគណៈកម្មាធិការចំនួន ០១រូប ប្រធានលេខាធិការ ០១រូប អនុប្រធានលេខាធិការ ០១រូប ) ក្រុមប្រឹក្សានីតិកម្មចំនួន ០៧រូប/ស្រី ០២រូប(ក្នុងនោះប្រធានចំនួន ០១រូប អនុប្រធានចំនួន ០៣រូប/ស្រី០១រូប សមាជិកចំនួន ០៣រូប/ស្រី០១រូប) លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិគ.ជ.អ.ប ចំនួន១៧រូប/ស្រី០៦រូប អគ្គាធិការចំនួន ០១រូប អគ្គាធិការរងចំនួន ០៩រូប/ស្រី ០១រូប ប្រធាននាយកដ្ឋានចំនួន ១២រូប/ស្រី ០១រូប អនុប្រធាននាយកដ្ឋានចំនួន ១៦៨រូប/ស្រី២៩រូប ប្រធានការិយាល័យចំនួន ៨៣រូប, ស្រី ១៩រូប អនុប្រធានការិយាល័យចំនួន ២៤៤រូប/ស្រី ៧១រូប និងមន្ត្រីចំនួន ៤០៤រូប/ស្រី ១១០រូប។

-មន្ត្រីដែលផ្ទេរភារកិច្ចពីថ្នាក់ក្រោមជាតិមកទីស្តីការក្រសួងចំនួន ១៨រូប/ស្រី០២រូប ស្មើនឹង១១,១១%

-មន្ត្រីរាជការក្របខ័ណ្ឌដែលមានមុខតំណែងជាទីប្រឹក្សា និងជំនួយការចំនួន ៥២៩រូប/ស្រី៥២រូបស្មើនឹង ៩,៨២%។ ដោយឡែកក្នុងខែមករាឆ្នាំ២០២០នេះ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃបានពិនិត្យ សម្រេចតែងតាំងមុខតំណែង ប្រគល់ភារកិច្ច ផ្លាស់ប្តូរកន្លែងធ្វើការ ជូនមន្ត្រីរាជការស៊ីវិលនៅថ្នាក់ជាតិសរុបចំនួន ៤០រូប/ស្រី០៤រូប។ ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាលក៏បាន និងកំពុងរៀបចំប្រកាសទ្រព្យសម្បត្តិតាមរបបកំណត់២ឆ្នាំ សម្រាប់ឆ្នាំ ២០២០ របស់មន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ ទីប្រឹក្សា និងជំនួយការផងដែរ។

### ៥.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

គិតត្រឹមខែមករា ឆ្នាំ២០២០ ស្ថានភាពបច្ចុប្បន្នភាពនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមន្ត្រីរដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសមានដូចខាងក្រោម ៖

-គណៈអភិបាលរាជធានី ខេត្តសរុបចំនួន១៧៥រូប/ស្រី២៧រូប ស្មើនឹង១៥,៤២% ក្នុងនោះ(អភិបាលរាជធានី ខេត្តចំនួន ២៥រូប/ស្រី០១រូប អភិបាលរងរាជធានី ខេត្តចំនួន ១៥០រូប/ស្រី២៦រូប)

-គណៈអភិបាលក្រុង ស្រុក ខណ្ឌសរុបចំនួន៩០៨រូប/ស្រី១៩២រូប ស្មើនឹង២១.១៤% ក្នុងនោះ(អភិបាលក្រុង ស្រុក ខណ្ឌចំនួន ១៩៧រូប/ស្រី០៧រូប អភិបាលរងក្រុង ស្រុក ខណ្ឌចំនួន ៧១១រូប/ស្រី ១៩១រូប)

-មន្ត្រីស្ថិតក្នុងចេនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌសរុបចំនួន ៦.៤៨៩រូប/ស្រី ២.១៥២រូប ស្មើនឹង ៣៣.១៦% ក្នុងនោះ(សាលារាជធានី ខេត្តចំនួន ២.៨០៩រូប /ស្រី៩១៥រូប ស្មើនឹង ៣២.៥៧% សាលាក្រុង ស្រុក ខណ្ឌចំនួន ៣.៦៨០រូប/ស្រី១.២៣៧រូប ស្មើនឹង ៣៣,៦១%) និងប្រធានទីស្នាក់ការច្រកទ្វារព្រំដែនចំនួន ៥៤រូប ។ ក្នុងខែមករា ឆ្នាំ២០២០នេះដែរ រាជរដ្ឋាភិបាល និងក្រសួងមហាផ្ទៃបានពិនិត្យ សម្រេចតែងតាំងមុខតំណែង ប្រគល់ភារកិច្ចជូនអភិបាល អភិបាលរងនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាលសាលាខេត្ត ក្រុង ស្រុក ខណ្ឌ និងផ្លាស់ប្តូរភារកិច្ច និងតែងតាំងស្មៀនឃុំ សង្កាត់សរុបចំនួន ៥០ រូប/ស្រី១២រូប (ដូចក្នុងឧបសម្ព័ន្ធ១ក-១ត)។

**៥.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

ស្ថានភាពបច្ចុប្បន្នភាពសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់ទូទាំងប្រទេសមានដូចខាងក្រោម៖

-សមាសភាពក្រុមប្រឹក្សារាជធានី ខេត្តសរុបចំនួន ៥៥៩រូប/ស្រី ៩៥រូប (ស្មើនឹង ១៦,៩៩%) ក្នុងនោះ (ប្រធានក្រុមប្រឹក្សារាជធានី ខេត្តចំនួន ២៥រូប សមាជិកក្រុមប្រឹក្សារាជធានី ខេត្តចំនួន ៥៣៤រូប/ស្រី ៩៥រូប)។

-សមាសភាពក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌសរុបចំនួន ៣.៥៥៥រូប/ស្រី៦២០រូប (ស្មើនឹង១៧,៤៩%)ក្នុងនោះ ប្រធានក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ២០៣រូប/ស្រី០៥រូប សមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ៣.៣៥២រូប/ស្រី៦១៥រូប។

-សមាសភាពក្រុមប្រឹក្សាឃុំ សង្កាត់សរុបចំនួន ១១.៥៧២រូប/ស្រី២.៣៩៦រូប(ស្មើនឹង២០.៧%)(ក្នុងនោះ មេឃុំចំនួន ១.៤១០រូប/ស្រី១០៨រូប ចៅសង្កាត់ចំនួន ២៣៦រូប/ស្រី២៦រូប ជំទប់ទី១ចំនួន ១.៤១០រូប /ស្រី ២២៧រូប ជំទប់ទី២ចំនួន ១.៤១០រូប/ស្រី៣១១រូប ចៅសង្កាត់រងទី១ ចំនួន ២៣៦រូប/ស្រី ៦០រូប ចៅសង្កាត់រងទី២ចំនួន ២៣៦ រូប/ស្រី៥៤រូប និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ចំនួន ៦.៦៣៤រូប/ស្រី ១.៦១០រូប)។ ក្នុងខែមករា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានផ្លាស់ប្តូរ និងទទួលស្គាល់សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ចំនួន ១៦រូប/ស្រី០៥រូប ក្នុងនោះសមាសភាពសមាជិកក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌចំនួន ០៣រូប/ស្រី០២រូប (ដូចក្នុងឧបសម្ព័ន្ធ២ក) និងសមាសភាពសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ចំនួន ១៣រូប/ស្រី០៣រូប(ដូចក្នុងឧបសម្ព័ន្ធ២ខ)។

**៥.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល**

ស្ថានភាពបច្ចុប្បន្នភាព នៃចំនួនប្រវត្តិរូបមន្ត្រីរាជការស៊ីវិលទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលបានបញ្ចូលក្នុងប្រព័ន្ធទិន្នន័យសរុបចំនួន ៩.៨០៣រូប/ស្រី ២.៧៥៦រូប(ក្នុងនោះមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិចំនួន ៨៨៨រូប/ស្រី ២០១រូប និងមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិចំនួន ៨.៩១៥រូប/ស្រី ២.៥៥៥រូប) ។ ក្នុងខែមករា ឆ្នាំ២០២០នេះ ផ្នែកបញ្ចូល និងគ្រប់គ្រងទិន្នន័យបានធ្វើបច្ចុប្បន្នភាពរួចរាល់ចំពោះគណៈអភិបាលខេត្ត ក្រុង ស្រុកចំនួន ០២ខេត្ត គឺខេត្តកំពង់ឆ្នាំង និងខេត្តឧត្តមមានជ័យ។

**៦-ការងារអភិវឌ្ឍន៍សមត្ថភាព**

**៦.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស**

ក្នុងខែមករាឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានចាត់បញ្ជូនមន្ត្រីរាជការស៊ីវិលចំនួន៦០រូប/ស្រី១៥រូប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០២០ នៅសាលាភូមិន្ទរដ្ឋបាល។ ទន្ទឹមនោះ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានរៀបចំវគ្គវិក្រឹត្យការមូលដ្ឋានដល់មន្ត្រីទីស្តីការក្រសួងមហាផ្ទៃ រដ្ឋបាលរាជធានីភ្នំពេញ និងរដ្ឋបាលខេត្តកណ្តាល ដែលមានសិក្ខាកាមចូលរួមចំនួន ៣៣រូប/ស្រី១៥រូប។

**៦.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន**

ក្នុងខែមករា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានចាត់បញ្ជូនមន្ត្រី ០១រូប ទៅសិក្សាវគ្គត្រៀមភាសាអង់គ្លេស ដើម្បីបន្តថ្នាក់អនុបណ្ឌិតនៅប្រទេសអង់គ្លេស ។ ជាមួយគ្នានោះដែរក៏បានរៀបចំសំណើសុំពន្យារលិខិតឆ្លងដែនផ្លូវការចំនួន ០១ច្បាប់ជូននាយករដ្ឋបាលសាលាខេត្តសៀមរាប ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលលើវិស័យទេសចរណ៍ នៅសាធារណរដ្ឋកូរ៉េ។

### ៦.៣-ការងារព័ត៌មាន និងផ្សព្វផ្សាយ

ចំពោះការងារព័ត៌មាន និងផ្សព្វផ្សាយ អគ្គនាយកដ្ឋានរដ្ឋបាលបាន និងកំពុងរៀបចំសេចក្តីព្រាងព្រឹត្តិបត្រ វិមជ្ឈការ និងវិសហមជ្ឈការលេខ០៤,បានធ្វើការបែងចែកព្រឹត្តិបត្រវិមជ្ឈការ និងវិសហមជ្ឈការក្រសួងមហាផ្ទៃ លេខ០៣ ទៅតាមបណ្តាក្រសួងចំនួន ២៨ និងបានបន្តធ្វើបច្ចុប្បន្នភាពគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃដោយបានបញ្ចូលអត្ថបទចំនួន ៣៤ករណី។ លើសពីនេះ ក៏បានផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការប្រឡងជ្រើសរើសនិស្សិតអាហារូបករណ៍ដើម្បីសិក្សានៅប្រទេសហុងគ្រី(HUNGRY) និងអាហារូបករណ៍ថ្នាក់បរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់របស់សាធារណរដ្ឋប្រជាមានិតចិន សម្រាប់ឆ្នាំសិក្សា២០២០-២០២១។

## ៧-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ

### ៧.១-ការងារគាំទ្របច្ចេកទេស និងអន្តរាគមន៍

ក្នុងកិច្ចគាំទ្របច្ចេកទេស និងអន្តរាគមន៍ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាលបានរៀបចំលិខិតក្នុងនាមក្រសួងមហាផ្ទៃដើម្បីស្នើសុំគោលការណ៍ដឹកនាំដ៏ខ្ពង់ខ្ពស់ពីប្រមុខរាជរដ្ឋាភិបាល និងបានផ្ញើលិខិតជម្រាបជូនទៅក្រសួង ស្ថាប័ន និងបានដាក់ចេញនូវគោលការណ៍ណែនាំដល់រដ្ឋបាល រាជធានី ខេត្តដូចខាងក្រោម៖

-សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ករណីរដ្ឋបាលខេត្តប៉ៃលិន ស្នើសុំសាងសង់ស្តូបមិត្តភាពកម្ពុជា-វៀតណាម។

-អគ្គស្នងការដ្ឋាននគរបាលជាតិ ករណីសំណើសុំឆ្លាក់ត្រាមូលទឹកថ្មីចំនួន ០២គ្រឿង(ក្នុងនោះជូនរដ្ឋបាល ស្រុកបាកាន ខេត្តពោធិ៍សាត់ ០១គ្រឿង និងរដ្ឋបាលឃុំបន្ទាយស្ទោង ស្រុកស្ទោង ខេត្តកំពង់ធំចំនួន ០១គ្រឿង)។

-រដ្ឋបាលខេត្តព្រះសីហនុ ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ ករណីស្តីពីលទ្ធផលនៃការចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាលក្នុងការិយបរិច្ឆេទ២០១៩។

-រដ្ឋបាលរាជធានីភ្នំពេញ

- ករណីឈ្មោះ មឿន សុខស៊ីថា ស្នើសុំជួយជំរុញទៅរដ្ឋបាលរាជធានីភ្នំពេញឱ្យចុះរៀបចំសណ្តាប់ធ្នាប់លើផ្លូវចេញចូលសាធារណៈត្រង់ចំណុចមុខផ្ទះរបស់ឈ្មោះ លិន ជា និងប្រពន្ធឈ្មោះ ជិម វត្តី មានទីតាំងស្ថិតនៅផ្ទះលេខ ៤១AZ0 ក្រុម៤៥ ភូមិ៤ ផ្លូវ៣៩៦ សង្កាត់បឹងកេងកង៣ ខណ្ឌបឹងកេងកង រាជធានី-ភ្នំពេញ ពីបទដាក់សម្ភារៈផ្សេងៗនៅផ្លូវ ៣៩៦ បាំងច្រកចេញចូលនាំឱ្យរំខានដល់ការរស់នៅ។
- ករណីឈ្មោះ ហ៊ុល មុំ ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខណ្ឌពោធិ៍សែនជ័យ ដែលបានចេញសេចក្តីជូនដំណឹងឱ្យរុះរើផ្ទះរបស់គាត់ស្ថិតនៅភូមិព្រៃព្រីងខាងត្បូង សង្កាត់ចោមចៅ២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

-រដ្ឋបាលខេត្តកំពត ករណីឈ្មោះ ឡី ណារី ស្នើសុំឱ្យរដ្ឋបាលស្រុកឈូក ខេត្តកំពត ធ្វើការអង្កេតស្រាវជ្រាវចំពោះការប្រឌិតឯកសារប្រថាប់ត្រា ដើម្បីធ្វើជាមធ្យោបាយប្រើប្រាស់បន្លំកាន់កាប់ដីធ្លីនៅឃុំឈូក និងឃុំបឹងនិមល

-រដ្ឋបាលខេត្តកោះកុង ករណី៖

- តំណាងប្រជាពលរដ្ឋ ១៩៧គ្រួសារ រស់នៅឃុំជីខលើ និងឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង ស្នើសុំជួយជំរុញ និងពន្លឿនការដោះស្រាយជម្លោះដីធ្លីរវាងប្រជាពលរដ្ឋចំនួន ១៩៧គ្រួសារ ជាមួយក្រុមហ៊ុនហេង ហ៊ុយ អេហ្គ្រីនខលឃ័រគ្រុប ស្ថិតនៅភូមិតានី ភូមិជីខ ភូមិឈូក ឃុំជីខលើ និងភូមិចំបក់ ឃុំជីខក្រោម ស្រុកស្រែអំបិល ខេត្តកោះកុង
- ឈ្មោះសេង លីន, សុខ មុំ, យី គន្ធា, ផាវ ញឹង, មិន អាន់,ខៀវ សុគន្ធ,ចាន់ វណ្ណា និងឈ្មោះស៊ឹម សុខឿន ស្នើសុំប្តឹងឈ្មោះ ឆាយ រី ពីបទញុះញង់ប្រជាពលរដ្ឋឱ្យលក់ដីសល់បំរុងទុករបស់សហគមន៍ ១៧៥គ្រួសារ មាន ៤៤ឡូតិ៍ ស្មើនឹង ១៣២ហិកតា នៅចំណុចព្រៃពាង គងធា(ប១៥) ភូមិជីខ ឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង
- សំណើសុំជួយអន្តរាគមន៍រកដំណោះស្រាយបញ្ចប់វិវាទដីធ្លីរវាងក្រុមហ៊ុន UnionDevelopmentGroup Co., ជាមួយប្រជាពលរដ្ឋ ២៦គ្រួសារ ដែលមានផ្ទៃដីទំហំ ៤៣២៧ហិកតា ស្រុកគិរីសាគរ និងស្រុកបូទុមសាគរ ខេត្តកោះកុង។
- ឈ្មោះ សែម ជី តំណាងប្រជាពលរដ្ឋ ១០គ្រួសារ រស់នៅឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ ខេត្តកោះកុង ស្នើសុំរកយុត្តិធម៌ ដោះស្រាយ និងជំរុញរកឱ្យក្រុមហ៊ុន Union Development Group co.,ltd ដែលបានរំលោភបំពានយកដីចំការប្រជាពលរដ្ឋដែលបានអាស្រ័យផលតាំងពីយូរមកហើយ។

•ឈ្មោះ ព្រាប រដ្ឋា តំណាងប្រជាពលរដ្ឋ ០៨គ្រួសារ រស់នៅឃុំព្រែកខ្សាច់ ស្រុកគិរីសាគរ ខេត្តកោះកុង ស្នើសុំកយុត្តិធម៌ ដោះស្រាយ និងជំរុញឱ្យក្រុមហ៊ុន SEZ របស់លោកឧកញ៉ា លី យ៉ុងផាត់ ដែលបានរំលោភបំពានយកដីចំការរបស់ប្រជាពលរដ្ឋដែលអាស្រ័យផលអស់រយៈពេលជាង១០ឆ្នាំមកម្លេះប្រគល់ជូនពួកគាត់វិញ។

-រដ្ឋបាលខេត្តសៀមរាប ករណី៖

•ស្នើសុំស្លាកលេខរដ្ឋ សម្រាប់ទោចក្រយានយន្តចំនួន ០៦គ្រឿង របស់ក្រុមការងារគម្រោងលើកកម្ពស់ដីភាពក្រីក្រ ខេត្តសៀមរាប

•ឈ្មោះ ផ្លែក សំណាង និងឈ្មោះ អៀ អេងថុង ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តសៀមរាបសហការជាមួយអយ្យការអមសាលាដំបូងខេត្តសៀមរាប ដើម្បីអនុវត្តសាលដីការលេខ ៣៣៤(ខ) ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ ២០១៩ របស់តុលាការកំពូល។

-រដ្ឋបាលខេត្តក្រចេះ ករណី៖

• ឈ្មោះឌី វ៉ាន់ឌឿន,ម៉ង់ សំភា, រត្ន សាលី និងឈ្មោះ ទូច ដារ៉ា ស្នើសុំអន្តរាគមន៍ទៅអភិបាលខេត្តក្រចេះ ឱ្យពួកគាត់បានកាន់កាប់ដីលំនៅដ្ឋាន ដែលស្ថិតនៅភូមិទី១ សង្កាត់កោកណ្តាល ក្រុងក្រចេះ ខេត្តក្រចេះ

•តំណាងប្រជាពលរដ្ឋ ២១គ្រួសារ នៅឃុំ២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ ស្នើសុំអន្តរាគមន៍ដោះស្រាយទំនាស់ដីធ្លី និងអន្តរាគមន៍ទៅអាជ្ញាធរពាក់ព័ន្ធ កុំឱ្យដកហូតដីធ្លីរបស់ពួកគាត់ទៅធ្វើសម្បទានដីសង្គមកិច្ចឱ្យពលរដ្ឋ ដែលមានទំនាស់ជាមួយក្រុមហ៊ុន ព្រោះដីនេះពួកគាត់បានកាន់កាប់អាស្រ័យផលតាំងពីឆ្នាំ២០០១

•គណបក្សកសិករ ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តក្រចេះ ដើម្បីជួយពិនិត្យសើរើឯកសារមិនប្រក្រតីដែលឈ្មោះ ហោ សុទ្ធារិន បានរំលោភបំពានដីធ្លី ស្ថិតនៅចំណុចយ៉ៃ ភូមិត្នោត ឃុំថ្មី ស្រុកចិត្របុរី ខេត្តក្រចេះ។

-រដ្ឋបាលខេត្តព្រះសីហនុ ករណី៖

•តំណាងប្រជាពលរដ្ឋ ៤៣គ្រួសារ រស់នៅឃុំអូរត្រេះ ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ ស្នើសុំអន្តរាគមន៍ទៅគណៈកម្មការដោះស្រាយវិវាទដីធ្លីខេត្តព្រះសីហនុ និងស្ថាប័នពាក់ព័ន្ធ ឱ្យធ្វើការវាស់វែង កាត់ឆ្វៀលដីលំនៅដ្ឋាន និងចំការទំហំ ៨៣ហិកតា សម្រាប់ដោះស្រាយជូនប្រជាពលរដ្ឋទាំង ៤៣គ្រួសារ

•ឈ្មោះ ហ៊ិន តារា និងឈ្មោះ ញ៉ា កែវឡាយ ស្នើសុំប្តឹងជំទាស់ទៅនឹងទិន្នន័យដែលបានបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ(ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី)តំបន់បានធ្វើការវិនិច្ឆ័យ ភូមិឬទ្ធី១ ឃុំកែវផុស ស្រុកស្ទឹងហាវ ខេត្តព្រះសីហនុ

•តំណាងប្រជាពលរដ្ឋ និងអាជីវករចំនួន ៦២គូប ស្នើសុំអន្តរាគមន៍ដោះស្រាយឱ្យពួកគាត់ដែលបានអាស្រ័យផល និងអនុញ្ញាតបន្តអាជីវកម្មនៅទីតាំងដដែល ស្ថិតនៅភូមិ៦ សង្កាត់លេខ៤ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ

•ឈ្មោះអ៊ុំ សំអុល និងឈ្មោះសឿ សុផល ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តព្រះសីហនុពន្លឿនការអនុវត្តស្មារតីលិខិតលេខ០៤៥/១៩លបក និងលិខិតលេខ ០៤៦/១៩លបក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តព្រះសីហនុ ដើម្បីចាត់មន្ត្រីជំនាញចុះពិនិត្យទីតាំងវាស់វែង និងកំណត់ព្រំដី ស្ថិតនៅតំបន់ចំការពេជ្រ ភូមិស្នាច់ដែង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

-រដ្ឋបាលខេត្តរតនគិរី ករណីក្រសួងបរិស្ថានស្នើសុំការអន្តរាគមន៍ទៅអាជ្ញាធរខេត្ត ស្រុក ឃុំ ដើម្បីទប់ស្កាត់ការកាប់ទន្ទ្រានដីព្រៃធ្វើជាកម្មសិទ្ធិ និងការបញ្ជាក់លើលិខិតទិញ-លក់ដីរដ្ឋ ដោយរដ្ឋបាលភូមិ ឃុំ ស្រុកក្នុងដែនជម្រកសត្វព្រៃលំផាត់ ខេត្តរតនគិរី។

-រដ្ឋបាលខេត្តកណ្តាល ករណីក្រុមហ៊ុន អាយអិនជី ហូលឌីង ស្នើសុំទប់ស្កាត់នូវការអនុវត្តនីតិវិធីចុះបញ្ជីដីទំហំប្រមាណ ១០០ហិកតា (បឹងរាម) មានទីតាំងស្ថិតនៅឃុំព្រែកអំពិល ស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល។

-រដ្ឋបាលខេត្តបន្ទាយមានជ័យករណីអង្គការអភិវឌ្ឍន៍សហគមន៍មូលដ្ឋានស្នើសុំបំភ្លឺលើលិខិតលេខ ៦០៨/១៩សជណ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៩ របស់រដ្ឋបាលខេត្តបន្ទាយមានជ័យស្តីពីការផ្អាកការជីកកាយ ក្រវ៉ាត់ព្រំឈូសឆាយសម្អាតដី និងសាងសង់សំណង់លើផ្ទៃដីទំហំ៧២១ហិកតា ស្ថិតនៅភូមិថ្នល់បត់ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

-រដ្ឋបាលខេត្តកំពង់ចាម ករណីឈ្មោះ ម៉ៅ យូហ៊ួ, ជា ស៊ាងហួត, សេង សុស, ថៃ ស្រេង និងឈ្មោះ គឹម វន្ថា ស្នើសុំលុបចោល "ករណីសំណើសុំកាត់ដីចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរបស់រដ្ឋរបស់រដ្ឋបាលស្រុកចំការលើ ខេត្តកំពង់ចាម ដើម្បីផ្តល់ជូនប្រជាពលរដ្ឋ និងមន្ត្រីរាជការចំនួន ១៩គ្រួសារ កាន់កាប់ជាកម្មសិទ្ធិស្របច្បាប់"។

-រដ្ឋបាលខេត្តកំពត ករណីស្នើសុំឱ្យរដ្ឋបាលស្រុកឈូក ធ្វើការអង្កេតស្រាវជ្រាវចំពោះការប្រឌិតឯកសារ ប្រថាប់ត្រា ដើម្បីធ្វើជាមធ្យោបាយបន្លំកាន់កាប់ដីធ្លីនៅឃុំឈូក និងឃុំបឹងនិមល។

-រដ្ឋបាលខេត្តកំពង់ធំ ករណីឈ្មោះ វ៉ាន់ សោភា, ជុំ តៅ និងឈ្មោះ ឡេង ប៊ុនថាត ស្នើសុំអន្តរាគមន៍ ដោះលែងឈ្មោះ យ៉ែម យន និងឈ្មោះ ជុំ វាសនា ដែលត្រូវបានចាប់ដាក់ឃុំ និងស្នើសុំឱ្យប្រជាពលរដ្ឋរស់នៅ ឃុំកំពង់គោ និងឃុំផាត់សណ្តាយ ស្រុកកំពង់ស្វាយ សង្កាត់កំពង់រទេះ សង្កាត់អូរគន្ធរ និងសង្កាត់ព្រៃតាហ៊ូ ក្រុងស្ទឹងសែន និងឃុំចំណាលើ ស្រុកស្ទោង បានប្រើប្រាស់ប្រព័ន្ធប្រឡាយទឹកព្រះគន្លង និងប្រឡាយទឹកព្រះស្ទែង។

**៧.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ**

បច្ចុប្បន្នព្រះរាជាណាចក្រកម្ពុជាមានរាជធានីចំនួន ០១ ខេត្ត២៤ ក្រុង២៧ ស្រុក១៦២ ខណ្ឌ១៤ ឃុំ១.៤០៥ សង្កាត់២៤១ និងភូមិចំនួន ១៤.៣៨៣។

**៧.៣-ការងារផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ**

ក្រសួងមហាផ្ទៃ បានលើកសំណើជូនរាជរដ្ឋាភិបាលកម្ពុជា ករណីស្នើសុំមេដាយព្រះរាជាណាចក្រកម្ពុជា ចំនួន ១៦គ្រឿង (ថ្នាក់មហាសេនាចំនួន ០៨គ្រឿង និងថ្នាក់ធិបឌិនចំនួន ០៨គ្រឿង) មេដាយមុនីសារាភ័ណ្ឌ ចំនួន ០៤គ្រឿង (ថ្នាក់មហាសេរីវឌ្ឍន៍ចំនួន ០២គ្រឿង និងថ្នាក់ធិបឌិនចំនួន ០២គ្រឿង) និងមេដាយស្ថាបនាជាតិចំនួន ៤២គ្រឿង (មេដាយថ្នាក់មាស ចំនួន ៤០គ្រឿង និងមេដាយថ្នាក់ប្រាក់ចំនួន ០២គ្រឿង) ដើម្បីផ្តល់ជូនសប្បុរសជន ដែលបានជួយកសាងសមិទ្ធផលជាច្រើននៅខេត្តតាកែវ ខេត្តបាត់ដំបង និងខេត្តព្រៃវែង ដោយចំណាយអស់ថវិកាសរុបចំនួន ២.៥០៤.០៦០ដុល្លារ(ពីរលានប្រាំរយបួនពាន់ហុកសិបដុល្លារអាមេរិក)(ដូចក្នុងឧបសម្ព័ន្ធ ៣)។

**៧.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា**

**៧.៤.១-កម្មវិធីគាំទ្រដោយអង្គការសហប្រជាជាតិសម្រាប់កុមារ UNICEF**

-បានចូលរួមកិច្ចប្រជុំជាមួយតំណាងអង្គការយូនីសេហ្វ ដើម្បីពិនិត្យពិភាក្សាលើសេចក្តីព្រាងផែនការសកម្មភាពនិងថវិកា ឆ្នាំ២០២០

-បានចូលរួមសិក្ខាសាលាស្តីពី "ការបញ្ជ្រាបគោលដៅអភិវឌ្ឍន៍ដោយចីរភាពកម្ពុជាទៅក្នុងផែនការថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ" ដែលរៀបចំដោយអង្គការយូនីសេហ្វ

-ប្រជុំត្រៀមរៀបចំកិច្ចប្រជុំ ដើម្បីពិនិត្យចំណុចសំខាន់ៗ នៃសៀវភៅណែនាំ ស្តីពីកម្មវិធីពានរង្វាន់ និងការទទួលស្គាល់សម្រាប់ការអនុវត្តសេវាសង្គមនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-ចូលរួមកិច្ចប្រជុំពិនិត្យរបាយការណ៍បឋម របស់ទីប្រឹក្សាស្តីពីការពិនិត្យឡើងវិញ និងការកែសម្រួលសេចក្តីណែនាំស្តីពីការរៀបចំ និងប្រព្រឹត្តិទៅរបស់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់

-បានប្រជុំណែនាំក្រុមការងារនៃរដ្ឋបាលខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ ស្តីពីការត្រៀមរៀបចំវគ្គបណ្តុះបណ្តាលសៀវភៅណែនាំស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍ សម្រាប់ឃុំ សង្កាត់

-ចូលរួមពិធីបើកដំណើរការអនុវត្តគម្រោងពង្រឹងការចូលរួមរបស់យុវជនក្នុងដំណើរការរៀបចំផែនការ និង ថវិកានៅកម្រិតមូលដ្ឋាន នៅខេត្តសៀមរាប និងខេត្តក្រចេះ

-សហការរៀបចំ និងចូលរួមសិក្ខាសាលាតម្រង់ទិសស្តីពីការឆ្លើយតបទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (CSDG) នៅក្នុងដំណើរការថវិកាថ្នាក់ក្រោមជាតិ។

**៧.៤.២-គម្រោងសាងសង់អាគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP**

គិតត្រឹមខែមករា ឆ្នាំ២០២០ ការវិវឌ្ឍនៃដំណើរការការដ្ឋានសាងសង់អគាររដ្ឋបាលស្រុក និងឃុំ សង្កាត់ គិតជារួមបានប្រមាណ៤០%។ ក្នុងខែមករា ឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានចាត់មន្ត្រីៈ

-តាមដាន និងសម្របសម្រួលទាក់ទងនឹងសំណើសុំថវិកាបន្ថែមទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីក្សាការសាងសងអគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគារដ្ឋបាលឃុំ សង្កាត់តាមចំនួនដែលបានគ្រោងទុក

-ចុះពិនិត្យតាមដានដំណើរការសាងសង់អគារសាលាស្រុកនិងអគាររដ្ឋបាលឃុំ សង្កាត់ដំណាក់កាលទី១និងទី២ ទន្ទឹមនេះក្រុមការងារគម្រោងក៏បានរៀបចំដំណើរការវាយតម្លៃកញ្ចប់លទ្ធកម្មទី១១ នៃគម្រោង។

**៧.៥-ការងារគម្រោងមូលនិធិ និងការគាំទ្រក្រុង ស្រុក ឃុំ សង្កាត់**

**៧.៥.១-គម្រោងមូលនិធិក្រុង ស្រុក**

គិតត្រឹមខែមករា ឆ្នាំ២០២០ សំណើគម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ២០១៩ មានចំនួន **៥១៦គម្រោង** ដែលក្នុងនោះៈ គម្រោងមិនទាន់សិក្សាចំនួន **២៧គម្រោង** (ស្មើនឹង៥,២៣%) គម្រោងកំពុងដំណើរការសិក្សាចំនួន **៥៦គម្រោង** (ស្មើនឹង១០,៨៥%) និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **៤៣៣គម្រោង**(ស្មើនឹង៨៣,៩២%) ហើយក្នុងចំណោមគម្រោងដែលបានបញ្ចប់ការសិក្សា មានគម្រោងចំនួន៣៩១**គម្រោង**(ស្មើនឹង៩០,៣០%) បានដេញថ្លៃរួចរាល់ ។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិក្រុង ស្រុកឆ្នាំ២០១៩ មានចំនួន **៣៤២កិច្ចសន្យា** ក្នុងនោះរួមមានៈ បញ្ចប់ការសាងសង់១០០% ចំនួន **២២២កិច្ចសន្យា** (ស្មើនឹង៦៤.៩១%) អនុវត្តបានលើស៥០% ចំនួន **៦៣កិច្ចសន្យា**(ស្មើនឹង១៨,៤២%) អនុវត្តបានតិចជាង៥០%ចំនួន **២៣កិច្ចសន្យា**(ស្មើនឹង៦,៧៣%) និងមិនទាន់បានអនុវត្តចំនួន **៣៤កិច្ចសន្យា**(ស្មើនឹង៩,៩៤%)។ ជាមួយគ្នានេះដែរ សំណើគម្រោងមូលនិធិក្រុង ស្រុក ឆ្នាំ២០១៨ មានចំនួន **៤៨៥គម្រោង** ដែលក្នុងនោះៈ គម្រោងមិនទាន់សិក្សាចំនួន **២៤គម្រោង**(ស្មើនឹង៤,៩៥%)និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន៤៦១**គម្រោង**(ស្មើនឹង៩៥,០៥%) ហើយក្នុងចំណោមគម្រោងដែលបានបញ្ចប់ការសិក្សាមានចំនួន៣៧៩គម្រោង(ស្មើនឹង៨២,២១%)បានដេញថ្លៃរួចរាល់។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិក្រុង ស្រុកឆ្នាំ២០១៨ មានចំនួន **៣៧៣កិច្ចសន្យា** ក្នុងនោះរួមមានៈ បានបញ្ចប់ការសាងសង់១០០% ចំនួន **៣៧១កិច្ចសន្យា** (ស្មើនឹង ៩៩,៤៦%) និងការអនុវត្តលើសពី៥០% ចំនួន **០២កិច្ចសន្យា**(ស្មើនឹង០,៥៤%)។

**៧.៥.២-គម្រោងមូលនិធិឃុំ សង្កាត់**

សំណើគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៩មានចំនួន **១.៧៤៨គម្រោង**(ក្នុងនោះគម្រោងដែលកំពុងសិក្សាចំនួន **០១គម្រោង** "ស្មើនឹង០,០៦%" និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **១.៧៤៧គម្រោង**(ស្មើនឹង៩៩,៩៤%)ហើយក្នុងចំណោមគម្រោងដែលបានបញ្ចប់ការសិក្សា មានគម្រោងចំនួន**១.៧៤៨** បានដេញថ្លៃរួចរាល់។ ចំពោះការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៩សរុបចំនួន **១.៦១០កិច្ចសន្យា** ក្នុងនោះរួមមានៈ ការអនុវត្តបានលើសពី៥០%ចំនួន **២៧០កិច្ចសន្យា**(ស្មើនឹង១៦,៧៧%) ការអនុវត្តបានតិចជាង៥០% ចំនួន**២០០កិច្ចសន្យា**(ស្មើនឹង១២,៤២%) បញ្ចប់ការសាងសង់១០០%ចំនួន **៧២៩កិច្ចសន្យា**(ស្មើនឹង៤៥,២៨%) និងមិនទាន់បានអនុវត្តចំនួន **៤១១កិច្ចសន្យា**(ស្មើនឹង២៥,៥៣%)។

ដោយឡែកការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ឆ្នាំ២០១៨មានចំនួន **១.៧៤៨គម្រោង**(ក្នុងនោះគម្រោងដែលកំពុងសិក្សាចំនួន **០១គម្រោង** "ស្មើនឹង០,០៦%" និងគម្រោងដែលបានបញ្ចប់ការសិក្សាចំនួន **១៧៤៧គម្រោង** ស្មើនឹង៩៩,៩៤%")ហើយក្នុងចំណោមគម្រោងដែលបានបញ្ចប់ការសិក្សាមានគម្រោងចំនួន **១៧៣៨** (ស្មើនឹង៩៩,៣៧%)បានដេញថ្លៃរួចរាល់។ ទន្ទឹមនោះ ការអនុវត្តកិច្ចសន្យាសាងសង់របស់គម្រោងមូលនិធិឃុំ សង្កាត់ ឆ្នាំ២០១៨សរុបចំនួន **១.៧៣៦កិច្ចសន្យា** ក្នុងនោះរួមមានៈ ការអនុវត្តបានលើសពី៥០%ចំនួន **៣៤កិច្ចសន្យា** (ស្មើនឹង១,៩៦%)ការអនុវត្តបានតិចជាង៥០%ចំនួន **១២កិច្ចសន្យា**(ស្មើនឹង ០,៦៩%) បញ្ចប់ការសាងសង់១០០%ចំនួន **១.៦៨០កិច្ចសន្យា**(ស្មើនឹង៩៦,៧៧%) មិនទាន់បានអនុវត្តចំនួន **០៨កិច្ចសន្យា**(ស្មើនឹង០,៤៦%) និងបោះបង់កិច្ចសន្យាចំនួន **០២កិច្ចសន្យា**(ស្មើនឹង០,១២%)។-

### ៧.៦-ការផ្តល់សេវា និងការដោះស្រាយវិវាទនៅមូលដ្ឋាន

#### ៧.៦.១-ការផ្ទេរមុខងារ និងធនធាន

បានរៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីការកំណត់មុខងារដែលត្រូវផ្ទេរប្រតិភូកម្មពីរដ្ឋបាលរាជធានីភ្នំពេញទៅឱ្យរដ្ឋបាលខណ្ឌនីមួយៗនៃរាជធានីភ្នំពេញជាមួយថ្នាក់ដឹកនាំ នៃរដ្ឋបាលរាជធានីភ្នំពេញ។

#### ៧.៦.២-ការផ្តល់សេវាតាមរយៈយន្តការច្រកចេញចូលតែមួយ

**ក.ការផ្តល់សេវាតាមរយៈអង្គភាពច្រកចេញចូលតែមួយ**

ក្នុងខែមករា ឆ្នាំ២០២០នេះ អង្គភាពច្រកចេញចូលតែមួយទាំង២៥រាជធានី ខេត្តបានផ្តល់សេវារដ្ឋបាលសរុបចំនួន ៥៤.០៥៣សេវា ក្នុងនោះបើប្រៀបធៀបចំនួនសេវាដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង១៤ឃើញថាវិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ផ្តល់សេវាបានច្រើនជាងគេគឺចំនួន ១៨.៤៧០សេវា (ស្មើនឹង ៣៤,១៧%)បន្ទាប់មកវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន ១១.១៨១សេវា (ស្មើនឹង២០,៦៩%) (ដូចក្នុងឧបសម្ព័ន្ធ៤)។ ជាមួយគ្នានេះដែរអង្គភាពច្រកចេញចូលតែមួយទាំង ២៥រាជធានី ខេត្តទទួលបានចំណូលសរុបចំនួន ៤.៨៨៤.៦៦០.០៨១រៀល (ស្មើនឹង១.២២១.១៦៥,០២០ដុល្លារអាមេរិក) ក្នុងនោះបើប្រៀបធៀបចំណូលដែលទទួលបាននៅក្នុងចំណោមវិស័យទាំង១៤ ឃើញថា វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ទទួលបានចំណូលខ្ពស់ជាងគេគឺ ៣.៥៤០.១៣៧.៦៨១រៀល (ស្មើនឹង៧២,៤៧%) បន្ទាប់មកវិស័យការងាររដ្ឋបាលទទួលបានចំណូលចំនួន ៣២២.៣៥៤.៥០០រៀល(ស្មើនឹង ៦,៦០%)(ដូចក្នុងឧបសម្ព័ន្ធ៥)។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាល បានអនុវត្តសកម្មភាពមួយចំនួនដើម្បីគាំទ្រដល់អង្គភាពច្រកចេញចូលតែមួយដូចខាងក្រោម៖

-បានដឹកនាំក្រុមការងារចុះត្រួតពិនិត្យមើលទីតាំងផ្តល់ការណែនាំ និងពិភាក្សាជាមួយរដ្ឋបាលខេត្តពោធិ៍សាត់អំពីការត្រៀមលក្ខណៈក្នុងការរៀបចំពិធីសម្ពោធ និងប្រកាសដាក់ឱ្យដំណើរការជាផ្លូវការនូវអង្គភាពច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ

-បានចុះសិក្សាលើទម្រង់បែបបទ និងនីតិវិធីក្នុងការផ្តល់សេវារបស់វិស័យរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ នៅសាលារាជធានីភ្នំពេញ

-បានសម្របសម្រួលជាមួយក្រសួងមួយចំនួន ដើម្បីពិនិត្យ និងកែសម្រួលលើទម្រង់ពាក្យស្នើសុំ និងសំណុំឯកសារភ្ជាប់នានា សម្រាប់ការផ្តល់សេវារដ្ឋបាលនៅអង្គភាពច្រកចេញចូលតែមួយ

-បានរៀបចំកិច្ចប្រជុំពិភាក្សាលើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រង និងការបែងចែកចំណូលកម្រៃសេវារបស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងលេខាធិការដ្ឋាន គ.ជ.អ.ប។

**ខ.ការផ្តល់សេវាតាមរយៈការិយាល័យច្រកចេញចូលតែមួយ**

ក្នុងខែមករា ឆ្នាំ២០២០នេះការិយាល័យច្រកចេញចូលតែមួយទាំង៨៣គោលដៅបានផ្តល់សេវារដ្ឋបាលសរុបចំនួន ១៦១.៩៦០សេវា បើប្រៀបធៀបចំនួនសេវាដែលបានផ្តល់នៅក្នុងចំណោមវិស័យទាំង១៤ ឃើញថាវិស័យនីត្យានុកូលកម្មបានផ្តល់សេវាបានច្រើនជាងគេគឺ ៦៥.០៧១សេវា(ស្មើនឹង៤០,១៨%)បន្ទាប់មកវិស័យសាធារណការនិងដឹកជញ្ជូនចំនួន ៤៥.៤៣៨សេវា (ស្មើនឹង២៨,០៦%) ចំពោះវិស័យដែលមិនបានផ្តល់សេវាគឺ វិស័យរ៉ែ និងថាមពល (ដូចក្នុងឧបសម្ព័ន្ធ៦)។ រយៈពេលដូចគ្នានេះដែរការិយាល័យច្រកចេញចូលតែមួយទាំង៨៣គោលដៅទទួលបានប្រាក់ចំណូលសរុបចំនួន១.៤៧៥.៧០៩.៥៩០រៀល(ស្មើនឹង ៣៦៨.៩២៧,៣៩៧ដុល្លារអាមេរិក) បើប្រៀបធៀបចំណូលដែលទទួលបានពីវិស័យទាំង១៤ឃើញថា វិស័យសុរិយោដីមានចំណូលខ្ពស់ជាងគេគឺ ចំនួន ៧៨៨.៨៣០.០០០រៀល(ស្មើនឹង៥៣,៤៥%)(ដូចក្នុងឧបសម្ព័ន្ធ៧)បន្ទាប់មកវិស័យសំណង់ទទួលបានចំណូលចំនួន ២៤៩.៩២៣.០០០រៀលស្មើនឹង១៦,៩៤% ចំពោះវិស័យដែលមិនទទួលបានចំណូលគឺវិស័យរ៉ែ និងថាមពល។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាល បានអនុវត្តសកម្មភាពមួយចំនួនដើម្បីគាំទ្រដល់ការិយាល័យច្រកចេញចូលតែមួយដូចខាងក្រោម៖

-គាំទ្រផ្នែកបច្ចេកទេសពាក់ព័ន្ធនឹងការផ្តល់សេវាតាមវិស័យជំនាញដល់ក្រុង ស្រុក ខណ្ឌមួយចំនួន

-ចូលរួមកិច្ចប្រជុំពិភាក្សាជាមួយក្រុមហ៊ុន លីហ្សូរ ផេប្ប៉ូ ស្តីពីការដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធទូទាត់ថ្លៃសេវារបស់ក្រុមហ៊ុនលីហ្សូរ នៅការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌចំនួន០៤គោលដៅរួមមាន ក្រុងបាត់ដំបង ស្រុកស្អាង ខណ្ឌកំបូល និងខណ្ឌបឹងកេងកង។

**៧.៦.៣-ការដោះស្រាយវិវាទរដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

**ក).ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត**

ក្នុងខែមករា ឆ្នាំ២០២០នេះ ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តបានទទួលបណ្តឹង សំណូមពរ ការទិតៀន ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធ និងមិនពាក់ព័ន្ធសរុបចំនួន **៤១ករណី** ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ចចំនួន**១២**ករណី បណ្តឹងក្រៅសមត្ថកិច្ចចំនួន **១៧**ករណីសំណូមពរចំនួន **០៩ករណី** និងការសាកសួរព័ត៌មានផ្សេងៗចំនួន០៣ករណី។ ជាមួយគ្នានេះដែរអគ្គនាយកដ្ឋានរដ្ឋបាលក៏បាន៖

-ចូលរួមកិច្ចប្រជុំជាមួយអង្គការតម្លាភាពដើម្បីស្នើសុំការគាំទ្រលើការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

-បានធ្វើបច្ចុប្បន្នភាពអំពីចំនួនបុគ្គលិកបំពេញការងារ សម្ភារប្រើប្រាស់ និងការរៀបចំផែនការសកម្មភាព និងថវិការបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្តសម្រាប់ឆ្នាំ២០២០

-បានពិនិត្យសំណើសុំប្រកាសទទួលស្គាល់ប្រធានការិយាល័យប្រជាពលរដ្ឋខេត្តតាកែវ

-បានរៀបចំលិខិតឆ្លើយតបទៅរដ្ឋបាលខេត្តកណ្តាល ស្តីពីការបោះឆ្នោតជ្រើសរើសអនុប្រធានការិយាល័យប្រជាពលរដ្ឋខេត្តកណ្តាលឡើងវិញ។

**ខ).ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ**

ក្នុងខែមករាឆ្នាំ២០២០នេះ ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌបានទទួលបណ្តឹង សំណូមពរ ការទិតៀន ការសរសើរ និងការសាកសួរព័ត៌មានផ្សេងៗពីប្រជាពលរដ្ឋដែលពាក់ព័ន្ធនិងមិនពាក់ព័ន្ធសរុបចំនួន **៨៦២ករណី** ក្នុងនោះបណ្តឹងក្នុងសមត្ថកិច្ច **១២**ករណី (បញ្ចប់ការដោះស្រាយ ០៥ករណី) និងបណ្តឹងក្រៅសមត្ថកិច្ចចំនួន **២៣**ករណី ការសរសើរចំនួន**៥៦**ករណី សំណូមពរចំនួន ៥៩ករណី ការសាកសួរព័ត៌មានផ្សេងៗចំនួន **៧១២**ករណី។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានរដ្ឋបាលក៏បានអនុវត្តកិច្ចការចាំបាច់មួយចំនួន ដើម្បីគាំទ្រដល់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌដូចខាងក្រោម៖

-បានតាមដាន និងគាំទ្រលើការដាក់ឱ្យដំណើរការរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ពាក់ព័ន្ធនឹងការតែងតាំងបុគ្គលិកសម្រាប់បំពេញការងារ ការបំពាក់សម្ភារប្រើប្រាស់ ការអនុវត្តតួនាទី ភារកិច្ច និងបញ្ហាប្រឈមនានារបស់ការិយាល័យនានារបស់ការិយាល័យប្រជាពលរដ្ឋនៅថ្នាក់ក្រោមជាតិ

-បានរៀបចំសំណើសុំប្រកាសទទួលស្គាល់ប្រធានការិយាល័យប្រជាពលរដ្ឋក្រុងខេមរៈភូមិន្ទ

-បានរៀបចំលិខិតឆ្លើយតបទៅរដ្ឋបាលស្រុកមណ្ឌលសីមា ស្តីពីការប្រកាសជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ

-បានគាំទ្រការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌអំពីប្រព័ន្ធកត់ត្រាបណ្តឹងនិងការរៀបចំរបាយការណ៍

-បានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានរៀបចំសេចក្តីណែនាំ ស្តីពីការវាយតម្លៃជ្រើសរើសរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានស្នាដៃល្អក្នុងការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ។

## ៨-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា

ក្នុងខែមករា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានធ្វើលិខិតជម្រាបជូនទៅក្រសួង ស្ថាប័ន និងអង្គភាពនានាដូចខាងក្រោម៖

-ក្រសួងការពារជាតិ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំយុវជន និងកីឡា ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងទេសចរណ៍ ក្រសួងសុខាភិបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គស្នងការដ្ឋាននគរបាលជាតិ និងរដ្ឋបាលខេត្តជាប់ព្រំដែនជាមួយប្រទេសថៃ ឱ្យផ្តល់របាយការណ៍ស្តីពីលទ្ធផលកិច្ចសហប្រតិបត្តិការ និងទិសដៅអនុវត្តការងារលើវិស័យនីមួយៗ រវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ខ្លួនជូនមកក្រសួងមហាផ្ទៃ ដើម្បីត្រៀមលក្ខណសម្បត្តិរៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃលើកទី៧ នាថ្ងៃ២២-២៤ ខែមេសា ឆ្នាំ២០២០ នៅទីក្រុងប៉ាតាយ៉ា នៃព្រះរាជាណាចក្រថៃ។

-ក្រសួងសាធារណការ និងដឹកជញ្ជូន ករណីសំណើសុំផ្តល់ផ្លាកលេខសម្គាល់យានយន្តរបស់អង្គការចំនួន៣។

-ធនាគារជាតិ នៃកម្ពុជា ករណីសំណើសុំផ្តល់របាយការណ៍វឌ្ឍនភាពលើការអនុវត្តអនុសាសន៍ក្នុងរបាយការណ៍វាយតម្លៃអមញ្ញឆ្នាំ២០១៧ជូនគណៈកម្មាធិការសម្របសម្រួលថ្នាក់ជាតិប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃករណី៖

• ហាងណារិទ្ធកាត់សក់បុរស-នារី ផ្ញើសារចូលក្នុងគេហទំព័រហ្វេសប៊ុករបស់ សម្តេចក្រឡាហោម ដើម្បីជួយអន្តរាគមន៍ដោះស្រាយដីមួយកន្លែងទំហំ ៤០ម៉ែត្រការ៉េ ស្ថិតនៅភូមិផ្លូវកអណ្តូង សង្កាត់ស្លក្រាមក្រុងសៀមរាប ខេត្តសៀមរាប។

• ឈ្មោះ ពេញ សុផាន់ណា ផ្ញើសារចូលក្នុងគេហទំព័រហ្វេសប៊ុករបស់ សម្តេចក្រឡាហោម ពាក់ព័ន្ធនឹងការប៉ះពាល់ដីចំណីផ្លូវក្នុងការអនុវត្តគម្រោងសាងសង់ប្រព័ន្ធលូប្រអប់កាត់ទទឹងផ្លូវ និងពង្រីកផ្លូវជាតិលេខ១ នៅក្រុងបាវិត។

-អគ្គលេខាធិការដ្ឋាននៃរដ្ឋសភា ករណីចុះបំពេញបេសកកម្មរបស់គណៈកម្មការទី៨ នៃរដ្ឋសភា។

-រដ្ឋបាលរាជធានី ខេត្ត ករណីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ស្នើសុំអញ្ជើញអភិបាលរងរាជធានី ខេត្ត ០១រូប ចូលរួមពិធីសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០២០។

-រដ្ឋបាលខេត្តមណ្ឌលគិរី រតនគិរី ស្ទឹងត្រែង ព្រះវិហារ កំពង់ធំ ពោធិ៍សាត់ បាត់ដំបង ប៉ៃលិន បន្ទាយមានជ័យ ឧត្តរមានជ័យ កំពង់ឆ្នាំង និងខេត្តសៀមរាប ករណីអគ្គលេខាធិការដ្ឋានរដ្ឋសភា ស្នើសុំជួយសម្រួលដល់ការចុះបំពេញបេសកកម្មរបស់គណៈកម្មការទី៤ ទី៦ ទី៨ និងទី៩ នៃរដ្ឋសភា។

-រដ្ឋបាលខេត្តឧត្តរមានជ័យ ករណីក្រសួងការពារជាតិស្នើសុំអញ្ជើញឯកឧត្តម អភិបាល នៃគណៈអភិបាខេត្ត និងអភិបាលរងខេត្តជាអធិបតីក្នុងពិធីបើក និងពិធីបិទ ព្រមទាំងចូលរួមក្នុងសិក្ខាសាលាស្តីពីការរៀបចំតំបន់ប្រវត្តិសាស្ត្រយោធា(អន្លង់វែង)។

-បានរៀបចំលិខិតជម្រាបជូនប្រធានក្រុមការងារថ្នាក់ជាតិ ចុះជួយមូលដ្ឋានរាជធានី ខេត្ត ដើម្បីអញ្ជើញជាអធិបតីក្នុង ពិធីបិទសន្និបាទបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ២០២០ របស់រដ្ឋបាលរាជធានី ខេត្ត។

## ៩.ការងារតាមវិស័យផ្សេងៗ

### ៩.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន

បច្ចុប្បន្ន ព្រះរាជាណាចក្រកម្ពុជា មានច្រកទ្វារព្រំដែនសរុបចំនួន ៨២ច្រក រួមមាន ច្រកទ្វារកំពង់ផែអន្តរជាតិចំនួន ០៣ច្រក ច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិចំនួន ០៣ច្រក ច្រកទ្វារព្រំដែនអន្តរជាតិចំនួន ២៦ច្រក ច្រកទ្វារព្រំដែនទ្វេភាគីចំនួន ១៤ច្រក ច្រកទ្វារតំបន់ព្រំដែនចំនួន ២៦ច្រក និងច្រកទ្វារកំពង់ផែសមុទ្រចំនួន ១០ច្រក។

ទន្ទឹមនេះ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានរៀបចំរបាយការណ៍ក្នុងនាមក្រសួងគោរពជូនប្រមុខរាជរដ្ឋាភិបាល និងបានធ្វើលិខិតជម្រាបជូនទៅក្រសួង ស្ថាប័ននានាពាក់ព័ន្ធនឹងការងារគ្រប់គ្រងច្រកទ្វារព្រំដែនដូចខាងក្រោម៖

**-សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី៖** អំពីរបាយការណ៍លទ្ធផល នៃកិច្ចប្រជុំលើកទី១ របស់ក្រុមការងារចំរុះស្តីពីច្រកទ្វារព្រំដែនគោកកម្ពុជា-វៀតណាមកាលពីថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០ នៅរដ្ឋធានីហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

-បានសម្របសម្រួលជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំក្រុមការងារចំរុះកម្ពុជាដើម្បីទៅចូលរួមកិច្ចប្រជុំលើកទី១ក្រុមការងារចំរុះស្តីពីច្រកទ្វារព្រំដែនគោកកម្ពុជា-វៀតណាមថ្ងៃទី០៩ ខែមករា ឆ្នាំ២០២០ នៅរដ្ឋធានីហាណូយ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម

**-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** ករណីស្នើសុំចាត់តំណាងក្រសួងមហាផ្ទៃចូលជាសមាជិកគណៈកម្មការអន្តរក្រសួងដោះស្រាយផលប៉ះពាល់ និងក្រុមការងារសម្រាប់ចុះអនុវត្តការងារដោះស្រាយផលប៉ះពាល់ដោយសារគម្រោងសាងសង់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនអន្តរជាតិម៉ឺនជ័យ។

គិតចាប់ពីថ្ងៃទី១៩ខែធ្នូ ដល់ថ្ងៃទី១៨ ខែមករា ឆ្នាំ២០២០ អគ្គនាយកដ្ឋានរដ្ឋបាលបានផ្តល់ប័ណ្ណព្រំដែនជូនរដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃសរុបចំនួន១៥.៤០០ក្បាល ក្នុងនោះរួមមាន៖(ខេត្តឧត្តរមានជ័យចំនួន៤.០០០ក្បាល បាត់ដំបងចំនួន៥.០០០ក្បាល ប៉ៃលិនចំនួន២.៤០០ក្បាល និងបន្ទាយមានជ័យចំនួន៤០០ក្បាល)។រដ្ឋបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃបានផ្តល់ប័ណ្ណព្រំដែនជូនប្រជាពលរដ្ឋប្រើប្រាស់ជាផ្លូវការសរុបចំនួន ១០.២២១ក្បាល ក្នុងនោះរួមមាន៖ (ខេត្តបាត់ដំបងចំនួន ៣.៥១៥ក្បាល ខេត្តបន្ទាយមានជ័យចំនួន ២.៣០១ក្បាល ខេត្តឧត្តរមានជ័យចំនួន ១.៨៣៧ក្បាល ប៉ៃលិនចំនួន ២.១៥៥ក្បាល និងខេត្តកោះកុងចំនួន ៤១៣ក្បាល)។

**៩.២-ការចងសម្ព័ន្ធមេត្រីភាព និងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ដើម្បីបង្កើនទំនាក់ទំនង ចងសម្ព័ន្ធមេត្រីភាពជាមិត្តភាព និងសហប្រតិបត្តិការជាមួយបណ្តាប្រទេសនានាជាមិត្ត ក្រសួងមហាផ្ទៃបានអនុញ្ញាតជាគោលការណ៍ឱ្យរដ្ឋបាលរាជធានី ខេត្តចុះហត្ថលេខាលើអនុស្សរណៈ(MOU) ផ្លាស់ប្តូរទស្សនៈកិច្ចសិក្សា និងកិច្ចសហប្រតិបត្តិការដូចខាងក្រោម៖

**-រដ្ឋបាលរាជធានីភ្នំពេញ** ករណីសំណើសុំគោលការណ៍អនុញ្ញាតឱ្យរដ្ឋបាលរាជធានីភ្នំពេញចុះហត្ថលេខាលើអនុស្សរណៈ នៃការយោគយល់គ្នាស្តីពីការបង្កើតចំណងមិត្តភាព រវាងរាជធានីភ្នំពេញ និងទីក្រុងណូវ៉ូស៊ីប៊ីល នៃសហព័ន្ធរុស្ស៊ី និងរាជធានីភ្នំពេញជាមួយទីក្រុងសេអ៊ូល នៃសាធារណរដ្ឋកូរ៉េ។

**-រដ្ឋបាលរាជធានីភ្នំពេញ និងខេត្តកណ្តាល** ស្នើសុំគោលការណ៍អនុញ្ញាតដឹកនាំប្រតិភូទៅចូលរួមទទួលរង្វាន់ជ័យលាភី "ទីក្រុងទេសចរណ៍ស្អាតអាស៊ានលើកទី២ សុពលភាពឆ្នាំ២០២០-២០២២" នៅរដ្ឋធានីបង់ដារសិរីបេហ្គាវ៉ាន់នៃប្រទេសប្រ៊ុយណេដារូសាឡឹម។

**-រដ្ឋបាលខេត្តសៀមរាប** ករណីរាជរដ្ឋាភិបាលឯកភាពជាគោលការណ៍អនុញ្ញាតឱ្យ៖

- រដ្ឋបាលខេត្តសៀមរាបធ្វើការកែសម្រួលលើខ្លឹមសារសេចក្តីព្រាង **"អនុស្សរណៈនៃការយោគយល់គ្នា"** ស្តីពីការចងសម្ព័ន្ធមេត្រីភាពមកជា **"កិច្ចព្រមព្រៀង"** ស្តីពីការចងសម្ព័ន្ធមេត្រីភាពរវាងខេត្តសៀមរាបជាមួយខេត្តក្រុងចំនួន ០២ នៃសាធារណរដ្ឋប្រជាមានិតចិន រួមមាន៖ ទីក្រុងឆុងឆីង និងខេត្តហៃណាន។
- ដឹកនាំគណៈប្រតិភូខេត្ត ទៅបំពេញទស្សនកិច្ចនៅខេត្តអូរសាកា នៃប្រទេសជប៉ុន។
- លោក នាក់ ណារ៉ុន អភិបាលរង នៃគណៈអភិបាលខេត្តសៀមរាប ទៅបំពេញទស្សនកិច្ចនៅខេត្តបុរីរ៉ាំ នៃព្រះរាជាណាចក្រថៃ
- ភាគីចិនមានបំណងបង្កើតចំណងសម្ព័ន្ធមេត្រីភាពរវាងក្រុងសៀមរាប និងក្រុងតាលី ខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន។

**- រដ្ឋបាលខេត្តបាត់ដំបង** បានសហការជាមួយគណៈកម្មាធិការសេដ្ឋកិច្ច និងសង្គមរបស់អង្គការសហប្រតិការសម្រាប់តំបន់អាស៊ីប៉ាស៊ីហ្វិក(UN-ESCAP) ដើម្បីអនុវត្តគម្រោង"ការអនុវត្តរបៀបវារៈឆ្នាំ២០៣០ក្នុងមូលដ្ឋានសម្រាប់ការគ្រប់គ្រងធនធានទីក្រុងប្រកបដោយចីរភាព(SURM) ក្នុងក្រុងបាត់ដំបង"

-រដ្ឋបាលខេត្តកោះកុង ករណីសំណើសុំគោលការណ៍អនុញ្ញាតឱ្យ៖

•ចុះហត្ថលេខា លើអនុស្សារណៈនៃការយោគយល់គ្នា ស្តីពីការបង្កើតចំណងទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការ រវាងខេត្តកោះកុង និងខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន

•ប្រតិភូខេត្តកោះកុងចំនួន ០៣រូប ទៅចូលរួមវេទិកាផ្កាថ្មអន្តរជាតិលើទី២ នៅក្រុងសានយ៉ាង ខេត្តហៃណាន នៃសាធារណរដ្ឋប្រជាមានិតចិន។

-រដ្ឋបាលខេត្តកំពង់ឆ្នាំង ករណីស្នើសុំគោលការណ៍អនុញ្ញាតឱ្យឯកឧត្តម អម សុភា អភិបាលរង នៃគណៈអភិបាលខេត្តកំពង់ឆ្នាំងទៅចូលរួមដំណើរទស្សនកិច្ចសិក្សាផ្លាស់ប្តូរបទពិសោធន៍នៅទីក្រុងកាត់មាន់ឌូ ប្រទេសនេប៉ាល់។

-រដ្ឋបាលខេត្តព្រះសីហនុ ករណីស្នើសុំគោលការណ៍អនុញ្ញាតឱ្យ៖

•ប្រតិភូខេត្ត ទៅបំពេញទស្សកិច្ចនៅខេត្តគៀនយ៉ាង និងខេត្តបាក់លីវ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

•ក្រសួងការពារជាតិ ស្នើសុំឱ្យគណៈប្រតិភូថៃដឹកនាំដោយឧត្តមនាវាទោ Southipong Anantachai មេបញ្ជាការរងបញ្ជាការដ្ឋានការពារព្រំដែនខេត្តត្រាត និងខេត្តចន្ទបុរី ចូលជួបសម្តែងការគួរសមជាមួយអភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ។

-អគ្គលេខាធិការ ក្រសួងមហាផ្ទៃ ករណីសំណើសុំផ្តល់ធាតុចូលស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យមួយចំនួនរវាងកម្ពុជា-នេប៉ាល់

-បន្តពិនិត្យ និងលើកយោបល់ ករណីឯកឧត្តម W. Patrick Murphy ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា គ្រោងនឹងទៅបំពេញទស្សនកិច្ចផ្លូវការនៅខេត្តកំពង់ធំ។

**៩.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ**

ក្នុងខែមករាឆ្នាំ២០២០នេះ អគ្គនាយកដ្ឋានរដ្ឋបាលបានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច លើសំណើសុំផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍន៍ឆ្នាំ២០១៩ចំនួន ៥៦គម្រោងរបស់រដ្ឋបាលរាជធានី ខេត្តចំនួន០៥រួមមាន៖ រាជធានីភ្នំពេញ(២១គម្រោង) ខេត្តកណ្តាល(៣គម្រោង) ខេត្តបន្ទាយមានជ័យ (២២គម្រោង)ខេត្តតាកែវ (៩គម្រោង) ខេត្តកំពត (១គម្រោង)មានទឹកប្រាក់សរុបចំនួន **២១៦.៥០៨.៩៩៧.០០០**រៀល (ពីររយដប់ប្រាំមួយប៊ីលានប្រាំរយប្រាំបីលានប្រាំបួនរយកៅសិបប្រាំពីរពាន់រៀលគត់)(ដូចក្នុងឧបសម្ព័ន្ធ៨)។ ទន្ទឹមនោះដែរ ក្រសួងមហាផ្ទៃក៏បានសម្រេចផ្តល់អនុលោមភាពលើគម្រោងអភិវឌ្ឍឆ្នាំ២០១៩ចំនួន៧២គម្រោងរបស់រដ្ឋបាលរាជធានីខេត្តចំនួន ៧២ រួមមាន៖ រាជធានីភ្នំពេញ(៣៤គម្រោង) ខេត្តកណ្តាល(២គម្រោង) ខេត្តបន្ទាយ-មានជ័យ(២៤គម្រោង) ខេត្តតាកែវ(២គម្រោង) ខេត្តកែប(៣គម្រោង) ខេត្តស្ទឹងត្រែង(៣គម្រោង) ខេត្តមណ្ឌលគិរី (៤គម្រោង) និងខេត្តរតនៈគិរី(១គម្រោង)មានទឹកប្រាក់សរុបចំនួន ២៨២.៧៣៣.៦២២.០០០រៀល (ពីររយប៉ែតសិបពីរប៊ីលានប្រាំពីររយសាមសិបបីលានប្រាំមួយរយម្ភៃពីរពាន់រៀលគត់)(ដូចក្នុងឧបសម្ព័ន្ធ៩)។

ទន្ទឹមនោះ អគ្គនាយកដ្ឋានរដ្ឋបាល ក៏បានរៀបចំលិខិតក្នុងនាមក្រសួងមហាផ្ទៃជម្រាបជូនទៅក្រសួងស្ថាប័ននានា និងរដ្ឋបាលខេត្តមួយចំនួនដូចខាងក្រោម៖

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ករណី៖

• រដ្ឋបាលរាជធានីភ្នំពេញស្នើសុំជម្រះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខណ្ឌសែនសុខចំនួន ០១ទីតាំង និងរដ្ឋបាលខណ្ឌពោធិ៍សែនជ័យចំនួន ០២ទីតាំង ព្រមទាំងស្នើសុំចាត់បញ្ជូនសមាសភាពចូលរួមក្នុងក្រុមការងារអន្តរក្រសួង ដើម្បីចុះពិនិត្យ និងវាយតម្លៃជាក់ស្តែងនូវឯកសារគតិយុត្តពាក់ព័ន្ធនឹងទីតាំងដីផ្សារពោធិ៍ចិនតុង។

•រដ្ឋបាលខេត្តកំពង់ឆ្នាំងស្នើសុំគោលការណ៍កាត់ចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលឃុំអណ្តូងស្នាយ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំងនូវដីទំហំ ៣០៦ម៉ែត្រការ៉េ និងអគារសង់នៅលើដីទំហំ ២២៥ម៉ែត្រការ៉េ ដើម្បីប្រទានកម្មជូនប្រជាពលរដ្ឋ។

• រដ្ឋបាលខេត្តកែបស្នើសុំផ្ទេរការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តកែបនូវដី(ស្រះទឹក) ទៅចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងយុត្តិធម៌ សម្រាប់សាងសង់អគារសាលាដំបូងខេត្តកែប។

• រដ្ឋបាលខេត្តប៉ៃលិនស្នើសុំដម្រុះដីទីលានសាធារណៈទំហំ២២.០៧២,៥០ម៉ែត្រការ៉េស្ថិតនៅភូមិទឹកថ្លា សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន ចេញពីក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តប៉ៃលិន។

**៩.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ**

**៩.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល**

គិតមកដល់បច្ចុប្បន្នសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះឈ្មោះក្នុងបញ្ជី នៅក្រសួងមហាផ្ទៃសរុបចំនួន ៥.៥៩៤ (ក្នុងនោះសមាគមចំនួន ២.២៦២ អង្គការមិនមែនរដ្ឋាភិបាលចំនួន ៣.៣៣២) និងសហគមន៍ជនជាតិដើមភាគតិចចំនួន១៤១ (ដូចក្នុងឧបសម្ព័ន្ធ១០)។ ក្នុងខែមករា ឆ្នាំ២០២០នេះ ក្រសួងមហាផ្ទៃបានចុះបញ្ជីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ២២ (ក្នុងនោះសមាគម១២ អង្គការមិនមែនរដ្ឋាភិបាល១០)។ ព្រមទាំងបានសម្រេចលុបឈ្មោះចេញពីបញ្ជីអង្គការមិនមែនរដ្ឋាភិបាល តាមការស្នើសុំសរុបចំនួន ៣) (ដូចក្នុងឧបសម្ព័ន្ធ១០) ជាមួយគ្នានេះផងដែរ ក៏បានបញ្ចូលទិន្នន័យស្តេនសំណុំឯកសារពាក់ព័ន្ធរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ៣១ច្បាប់ ក្នុងនោះសមាគមចំនួន ២១ច្បាប់ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១០ច្បាប់។

ទន្ទឹមនេះ ក៏បានពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេចពាក់ព័ន្ធនឹងការងារនានាដូចជាការសុំចុះឈ្មោះក្នុងបញ្ជីសមាគម អង្គការមិនមែនរដ្ឋាភិបាល ការសុំទទួលស្គាល់ប្រធាន ការសុំផ្លាស់ប្តូរសមាសភាពថ្មី នៃរចនាសម្ព័ន្ធ ការសុំធ្វើវិសោធនកម្មលក្ខន្តិកៈ ការសុំបើកទីស្នាក់ការសាខា ការសុំប្តូរឈ្មោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ការលុបឈ្មោះ ការផ្អាកសកម្មភាពបណ្តោះអាសន្នចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

**៩.៤.២-ការងារគណបក្សនយោបាយ**

គិតមកដល់បច្ចុប្បន្នគណបក្សនយោបាយមានចំនួនសរុប ៤៦គណបក្ស ក្នុងនោះគណបក្សដែលបានចុះបញ្ជីមានចំនួន ៤៣គណបក្ស និងគណបក្សដែលបានបង្កើតមានចំនួន ០៣គណបក្ស ។ ទន្ទឹមនេះ ក្រសួងមហាផ្ទៃក៏បានសម្រេចលើការស្នើសុំបង្កើតគណបក្សចំនួន០២គឺ គណបក្សកម្លាំងប្រជាធិបតេយ្យ និងគណបក្សខ្មែរស្រលាញ់ជាតិ (ដូចក្នុងឧបសម្ព័ន្ធ១០)។

**II-បញ្ហាប្រឈម និងសំណូមពរ**

ទន្ទឹមនឹងការសម្រេចលទ្ធផលដូចខាងលើ ក្នុងការបំពេញការកិច្ចកន្លងមក អគ្គនាយកដ្ឋានរដ្ឋបាលបានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដូចខាងក្រោម៖

-ការបញ្ជូនឯកសារពីក្រសួងមហាផ្ទៃទៅកាន់រដ្ឋបាលរាជធានី ខេត្ត និងការបញ្ជូនឯកសារពីរដ្ឋបាលរាជធានី ខេត្តមកក្រសួងមហាផ្ទៃនៅតែមានភាពយឺតយ៉ាវ

-ការផ្គត់ផ្គង់សម្ភារៈការិយាល័យដូចជាក្រដាសទឹកថ្នាំ ម៉ាស៊ីនថតចម្លងដើម្បីឆ្លើយតបសំណូមពរការងារមិនបានគ្រប់គ្រាន់

-ការផ្គត់ផ្គង់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មសម្រាប់មន្ត្រីចុះបំពេញការងារនៅតាមខេត្ត មន្ត្រីរាជការត្រូវចំណាយថវិកាផ្ទាល់ខ្លួនជាមុនហើយបន្ទាប់ពីបញ្ចប់បេសកកម្មការបើកផ្តល់មានភាពយឺតយ៉ាវ។

ដើម្បីជំរុញការអនុវត្តការងារឱ្យមានប្រសិទ្ធភាព ក៏ដូចជាការលើកទឹកចិត្តមន្ត្រី ក្នុងការបំពេញការងារ អគ្គនាយកដ្ឋានរដ្ឋបាល សំណូមពរដូចខាងក្រោម៖

-ផ្គត់ផ្គង់សម្ភារការិយាល័យឱ្យបានសមស្រប និងទាន់ពេលវេលាដើម្បីជានាឆ្លើយតបសំណូមពរការងារ

-ផ្តល់ប្រេងឥន្ធនៈ និងប្រាក់បេសកកម្មឱ្យបានលឿនជាងមុនបន្ទាប់ពីចុះបំពេញបេសកកម្ម។

**III-ទិសដៅការងារបន្ត**

ដើម្បីជំរុញការអនុវត្តការងារឱ្យបានល្អប្រសើរ និងតាមផែនការដែលបានគ្រោងទុក អគ្គនាយកដ្ឋានរដ្ឋបាលបានដាក់ចេញនូវទិសដៅការងារបន្តសម្រាប់ខែកុម្ភៈឆ្នាំ២០២០ ដូចខាងក្រោម៖ -

## ១-ការងាររៀបចំលិខិតបទដ្ឋានគតិយុត្ត

### ១.១-លិខិតបទដ្ឋានគតិយុត្តផ្ទៃក្នុងដែលកំពុងរៀបចំ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីឯកសណ្ឋានការងាររបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីរបបសោធននិវត្តន៍ និងសោធនបាត់បង់សម្បទាវិជ្ជាជីវៈ ចំពោះក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីគោលការណ៍ និងនីតិវិធីនៃការបង្កើត និងការលុបចោលភូមិ និងការកែសម្រួលព្រំប្រទល់រដ្ឋបាល នៃរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងវិសោធនកម្មអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃសាលាជាតិរដ្ឋបាលមូលដ្ឋាន

-សេចក្តីព្រាងប្រកាសស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅ នៃអង្គភាពចំណុះសាលាជាតិរដ្ឋបាលមូលដ្ឋាន និងឯកសារពាក់ព័ន្ធ

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីការអនុវត្តប្រកាសស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីនីតិវិធីនៃការផ្លាស់ប្តូរ និងតែងតាំងស្មៀនឃុំ សង្កាត់

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីបែបបទ និងនីតិវិធីនៃការផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីនីតិវិធី នៃការសុំច្បាប់ឈប់សម្រាករបស់ប្រធានក្រុមប្រឹក្សារាជធានី ខេ ក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាង សេចក្តីណែនាំស្តីពីការចេញប័ណ្ណសម្គាល់ខ្លួនសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សេចក្តីព្រាងសេចក្តីណែនាំស្តីពីរបៀបបធ្វើការងាររបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

-សេចក្តីព្រាងសៀវភៅណែនាំស្តីពី«កិច្ចការរដ្ឋបាល»សម្រាប់ប្រើប្រាស់នៅតាមអង្គភាពនានា(ផ្នែករដ្ឋបាលស៊ីវិល) ចំណុះទីស្តីការក្រសួងមហាផ្ទៃ

-សេចក្តីព្រាងគំរូដីកា ស្តីពីការផ្ទេរប្រតិភូកម្មការធ្វើប្រតិភូកម្មមុខងារក្នុងវិស័យនានា ទៅឱ្យរដ្ឋបាលខណ្ឌទាំងអស់ នៃរាជធានីភ្នំពេញ

-សេចក្តីព្រាងគំរូកិច្ចសន្យា ស្តីពីការផ្តល់សេវាកម្មសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមសំណល់រឹងទីប្រជុំជន របស់រដ្ឋបាលក្រុង ស្រុក

-សេចក្តីព្រាងក្របខ័ណ្ឌតាមដានត្រួតពិនិត្យវាយតម្លៃលើផែនការយុទ្ធសាស្ត្រស្តីពីការអភិវឌ្ឍសមត្ថភាព មន្ត្រីរាជការស៊ីវិលនៅក្រសួងមហាផ្ទៃ និងធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងសៀវភៅស្តីពីអភិបាលកិច្ចមូលដ្ឋាននៅកម្ពុជា

-សេចក្តីព្រាងស្តង់ដារអតិបរមាសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិល នៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបា ថ្នាក់ក្រោមជាតិ។

### ១.២-លិខិតបទដ្ឋានគតិយុត្តដែលសហការរៀបចំជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ

-សេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ

-សេចក្តីព្រាងក្រមប្រតិបត្តិសម្រាប់អ្នករាជការសាធារណៈ

-សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃអង្គរដ្ឋបាលសម្រាប់មន្ត្រីរាជការស៊ីវិល

-សេចក្តីព្រាងអនុក្រឹត្យស្តីពី ការគ្រប់គ្រង និងការបែងចែកចំណូល ដែលបានមកពីការផ្តល់សេវារដ្ឋបាល របស់អង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-សេចក្តីព្រាងអនុក្រឹត្យស្តីពីកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនស្ត្រីមានផ្ទៃពោះនិងកុមារអាយុក្រោម០២ឆ្នាំ ក្នុងគ្រួសារក្រីក្រ

-សេចក្តីព្រាងអនុក្រឹត្យស្តីពីការកែសម្រួលអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ

-សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពី ការកែសម្រួលប្រកាសអន្តរក្រសួងលេខ១៤៣៤២ប្រ.ក ចុះថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០១៦ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-សេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីការប្រមូលចំណូលពីការលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រ ខេត្តបាត់ដំបង

-សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពីការបែងចែកចំណូលពីថ្លៃលក់សំបុត្រចូលទស្សនាសារមន្ទីរប្រវត្តិសាស្ត្រ ខេត្តបាត់ដំបង

-សេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាលរាជធានី ខេត្ត

-សេចក្តីព្រាងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈឆ្នាំ២០១៩-២០៣០។

## ២-ការងារបុគ្គលិក

### ២.១-ការងារក្របខ័ណ្ឌ

-បន្តរៀបចំបែបបទសុំប្រឡងជ្រើសរើស និស្សិត ឱ្យចូលបម្រើការងារក្នុងក្របខណ្ឌមន្ត្រីរាជការមហាផ្ទៃ ក្នុងផែនការក្របខណ្ឌឆ្នាំ២០២០

-បន្តរៀបចំបែបបទស្នើសុំផ្ទេរក្របខ័ណ្ឌពីមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ ទៅក្នុងក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗ និងពីក្របខ័ណ្ឌក្រសួង-ស្ថាប័នផ្សេងៗមកក្នុងក្របខ័ណ្ឌមន្ត្រីរាជការស៊ីវិល និងក្របខ័ណ្ឌមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ដើម្បីទៅបំពេញការងារក្នុងមុខតំណែងថ្មី និងអនុញ្ញាតឲ្យមន្ត្រីរាជការចូលបម្រើការងារក្នុងក្របខ័ណ្ឌដើមវិញ

-បន្តរៀបចំបែបបទដើម្បីតាំងស៊ប់ជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទ ដើម្បីសុំពិនិត្យនីត្យានុកូលភាពលើប្រកាសតែងតាំង និងប្រគល់ភារកិច្ច ដើម្បីស្នើសុំផ្តល់ប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទផ្តល់ទិដ្ឋាការលើសលាកបត្រជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ក្រសួងមហាផ្ទៃ។

### ២.២-ការងារគោលនយោបាយមន្ត្រីរាជការស៊ីវិល

-រៀបចំពិនិត្យផ្ទៀងផ្ទាត់សលាបត្រមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ ដែលដល់អាយុត្រូវចូលនិវត្តន៍ឆ្នាំ២០២០

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីរាជការដែលទទួលមរណភាពនិងមន្ត្រីរាជការដែលសុំលាឈប់ពីការងារ

-បន្តរៀបចំការផ្តល់ប័ណ្ណសម្គាល់ខ្លួនជូនមន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទដាក់មន្ត្រីរាជការឲ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ

-បន្តរៀបចំសំណុំលិខិតអនុញ្ញាត ឱ្យមន្ត្រីរាជការចូលបម្រើការងារនៅអង្គភាពដើមវិញ បន្ទាប់ពីសុំស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សតាមការស្នើសុំ

-បន្តរៀបចំសំណុំលិខិតលុបឈ្មោះមន្ត្រីដែលស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយហួសកាលកំណត់

-បន្តរៀបចំសំណុំលិខិតអនុញ្ញាតឈប់សម្រាកលំហែមាតុភាព

-បន្តរៀបចំសំណុំបែបបទផ្ទេរកូនកំព្រា និងសុំប្រាក់ជានាវ៉ាប់រងសង្គម

-បន្តពិនិត្យផ្ទៀងផ្ទាត់ការស្នើសុំគ្រឿងឥស្សរិយយសមេដាយការងារ និងប័ណ្ណសរសើ ជូនមន្ត្រីរាជការស៊ីវិល។

### ២.៣-ការងារបុគ្គលិករដ្ឋបាលថ្នាក់ជាតិ

-បន្តរៀបចំផ្លាស់ប្តូរកន្លែងធ្វើការ រៀបចំដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិរយៈពេល ០៣ ខែសម្រាប់មន្ត្រីរាជការស៊ីវិល និងដាក់ទណ្ឌកម្មខាងវិន័យសម្រាប់មន្ត្រីពន្ធនាគារនិងរៀបចំតារាងបៀវត្សកែតម្រូវឱ្យត្រូវតាមរចនាសម្ព័ន្ធនៃអង្គភាពនីមួយៗ

-បន្តរៀបចំធ្វើបញ្ជីបច្ចុប្បន្នភាព និងតែងតាំងទីប្រឹក្សា ជំនួយការក្រសួងមហាផ្ទៃ និងទីប្រឹក្សា ជំនួយការសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

-បន្តរៀបចំធ្វើបច្ចុប្បន្នភាពសម្រាប់ខែបន្ទាប់របស់មន្ត្រីរាជការស៊ីវិលនិងមន្ត្រីពន្ធនាគារឱ្យមានភាពត្រឹមត្រូវនៅទីស្តីការក្រសួងមហាផ្ទៃ

-បន្តរៀបចំក្រុមការងារពិពណ៌នាមុខតំណែងមន្ត្រីរាជការ។

**២.៤-ការងារបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តចូលរួមសហការជាមួយអង្គភាពពាក់ព័ន្ធក្នុងការចុះសិក្សាស្រាវជ្រាវ និងចុះតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការបំពេញតួនាទីភារកិច្ច ការពង្រឹងរបៀបរបបបំពេញការងារ និងការគ្រប់គ្រងមន្ត្រី នៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-ពិនិត្យ និងសិក្សាលើសំណើសុំកែសម្រួលរចនាសម្ព័ន្ធទីចាត់ការ អង្គភាព និងការិយាល័យនានានៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តពិនិត្យ និងលើកយោបល់ ដើម្បីស្នើសុំការសម្រេចលើការតែងតាំងគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវដល់អាណត្តិ ០៤ឆ្នាំ( និង០៨ឆ្នាំ )របស់ខ្លួន

-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បន្តសហការជាមួយលេខាធិការ គ.ជ.អ.ប ក្នុងការពិនិត្យផ្ទៀងផ្ទាត់លើបញ្ជីមន្ត្រីរាជការដែលបានធ្វើសមាហរណកម្ម ទៅក្នុងរចនាសម្ព័ន្ធថ្មី នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តសហការ និងសម្របសម្រួលរៀបចំពិធីប្រកាសចូលកាន់មុខតំណែងរបស់មន្ត្រីរាជការ ក្នុងរចនាសម្ព័ន្ធថ្មី នៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**២.៥-ការងារក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តយកចិត្តទុកដាក់ពិនិត្យលើកយោបល់ទាក់ទងការផ្លាស់ប្តូរ និងទទួលស្គាល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ឱ្យបានទាន់ពេលវេលា

-បន្តធ្វើបច្ចុប្បន្នភាពបញ្ជីក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ.ឃុំ សង្កាត់។

**២.៦-ការងារគ្រប់គ្រងទិន្នន័យមន្ត្រីរាជការស៊ីវិល**

-សិក្សា និងរៀបចំភ្ជាប់ប្រព័ន្ធគ្រប់គ្រងទិន្នន័យគ្រប់ការិយាល័យដែលពាក់ព័ន្ធចំណុះនាយកដ្ឋានបុគ្គលិក

-បន្តសហការជាមួយក្រុមហ៊ុនក្នុងការរៀបចំប្រព័ន្ធឲ្យមានភាពល្អប្រសើរជាងមុន

-បន្តធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការស៊ីវិល ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាបន្តបន្ទាប់

-បន្តសហការជាមួយមន្ត្រីបង្គោល នៃរដ្ឋបាលរាជធានី ខេត្ត ដើម្បីប្រមូលប្រវត្តិរូបមន្ត្រីកម្មសិក្សាក្របខ័ណ្ឌ ថ្មី ឆ្នាំ២០២០ និងមន្ត្រីដែលទើបផ្ទេរចូលថ្មី រួមទាំងឯកសារមន្ត្រីរាជការដែលមានការប្រែប្រួលស្ថានភាពជាបន្ត បន្ទាប់

-ធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការដូចជាការផ្លាស់ប្តូរទីកន្លែងធ្វើការ ការតែងតាំង ការប្រែប្រួលថ្នាក់ ឋានន្តរស័ក្តិ ការលុបឈ្មោះ ការចូលនិវត្តន៍...។ល។ ទៅក្នុងប្រព័ន្ធ។

**៣-ការងារអភិវឌ្ឍន៍សមត្ថភាព**

**៣.១-ការងារអភិវឌ្ឍន៍សមត្ថភាពក្នុងប្រទេស**

-ត្រៀមរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់រាជធានី ខេត្ត ស្របតាមផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ ស្តីពីការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-រៀបចំវគ្គបណ្តុះបណ្តាលសម្រាប់ក្រុមគោលដៅជាមន្ត្រីនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

-បន្តរៀបចំឯកសារបណ្តុះបណ្តាលសម្រាប់ស្មៀនឃុំ សង្កាត់

-បន្តចងក្រងទិន្នន័យអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការ

-រៀបចំកិច្ចការចាំបាច់នានាសម្រាប់ដាក់ឲ្យដំណើរការសាលាជាតិរដ្ឋបាលមូលដ្ឋាន (NASLA)

-សិក្សាស្រាវជ្រាវ និងចងក្រងឯកសារអភិបាលកិច្ចមូលដ្ឋាន។

**៣.២-ការងារអភិវឌ្ឍន៍សមត្ថភាពក្រៅប្រទេស និងលិខិតឆ្លងដែន**

-បន្តរៀបចំបែបបទដើម្បីបញ្ជូនមន្ត្រីទៅចូលរួមសកម្មភាពអភិវឌ្ឍន៍សមត្ថភាពនៅក្រៅប្រទេស

-បន្តសហការជាមួយដៃគូ ដើម្បីស្វែងរកការគាំទ្រ និងកិច្ចសហការសម្រាប់ការអភិវឌ្ឍសមត្ថភាពដល់មន្ត្រីរាជការស៊ីវិល ក្រសួងមហាផ្ទៃ

-បន្តរៀបចំបែបបទ ដើម្បីស្នើសុំលិខិតឆ្លងដែនការទូត និងផ្លូវការតាមការស្នើសុំពីមន្ត្រីរាជការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

**៣.៣-ការងារផ្សព្វផ្សាយ និងព័ត៌មាន**

-បន្តធ្វើបច្ចុប្បន្នភាពនិងបញ្ចូលអត្ថបទក្នុងគេហទំព័រអគ្គនាយកដ្ឋានរដ្ឋបាល

-បន្តស្រាវជ្រាវ និងសរសេរអត្ថបទដើម្បីបញ្ចូលទៅក្នុងព្រឹត្តិបត្រ «វិមជ្ឈការ និងវិសហមជ្ឈការ» ក្រសួងមហាផ្ទៃលេខ ០៤។

**៤-ការងារគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ**

**៤.១-ការងារគាំទ្របច្ចេកទេស និងអន្តរាគមន៍**

ដើម្បីគាំទ្រដល់ការបំពេញតួនាទីភារកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានរដ្ឋបាលបន្តពិនិត្យលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច និងបន្តអនុវត្តលើកិច្ចការមួយចំនួនដូចខាងក្រោម៖

-រដ្ឋបាលរាជធានីភ្នំពេញ ករណីឈ្មោះ សាម សំណាង, ម៉ៅ ពៅ, ម៉ៅ សារឿន, គាន បុប្ផា, ជា សំអូន, អ៊ុច ពន្លក, ឈិត សុឃឿន និងឈ្មោះ ប៊ុន សុខា ស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលរាជធានីភ្នំពេញដើម្បីចេញប័ណ្ណកម្មសិទ្ធិកាន់កាប់ដីលំនៅឋានទៅតាមទំហំទីតាំងជាក់ស្តែងដែលបានកាន់កាប់ និងអាស្រ័យផល។

-រដ្ឋបាលខេត្តប៉ៃលិន ករណីស្នើសុំទទួលស្គាល់នូវនិមិត្តសញ្ញារបស់រដ្ឋបាល ខេត្តប៉ៃលិន។

-រដ្ឋបាលខេត្តកណ្តាល ករណីតំណាងប្រជាពលរដ្ឋចំនួន ១៤គ្រួសារ ស្នើសុំអន្តរាគមន៍ជួយដោះស្រាយទំនាស់ដីធ្លីមួយកន្លែង ស្ថិតនៅភូមិសាលាតាព្រហ្ម ឃុំបឹងខ្យាង ស្រុកកណ្តាលស្ទឹង។

-រដ្ឋបាលខេត្តព្រះសីហនុ៖

• ករណីតំណាងប្រជាពលរដ្ឋ ២៥គ្រួសារ ស្នើសុំអន្តរាគមន៍ទប់ស្កាត់ឈ្មោះ វ៉ន់ ណូ បច្ចុប្បន្នជាមេឃុំអណ្តូងថ្មឱ្យបញ្ឈប់ធ្វើសកម្មភាពឈូសឆាយរំលោភយកដីរបស់ពួកគាត់ ស្ថិតនៅក្នុងភូមិត្រពាំងស្អុយ១ ភូមិត្រពាំងស្អុយ២ភូមិអណ្តូងថ្ម ឃុំអណ្តូងថ្ម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ។

• ករណីសមាគមអ្នកគាំពារសុខភាពពលរដ្ឋកម្ពុជាស្នើសុំបង្កើត និងកសាងមជ្ឈមណ្ឌលតេជោហ៊ុនសែនសន្តិភាពគាំពារព្យាបាលចាស់ជរាកម្ពុជា ស្ថិតនៅទីតាំងចំណុចជាប់ជើងភ្នំស៊ីម៉ូលី ភូមិស្ទឹងសំរោង ឃុំអូរបាក់រទេះ ស្រុកកំពង់សិលា ខេត្តព្រះសីហនុ លើដីទំហំ ៦១៦ហិកតា។

-រដ្ឋបាលខេត្តបន្ទាយមានជ័យ ករណី៖

• ឈ្មោះអ៊ូ ប៊ុនណារិទ្ធស្នើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តបន្ទាយមានជ័យ ដើម្បីធ្វើប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុមួយកន្លែង ស្ថិតនៅភូមិអណ្តូងថ្មមាស សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

• ឈ្មោះ ង៉ាន ហ្សារីតា សំណើសុំអន្តរាគមន៍ទៅរដ្ឋបាលខេត្តបន្ទាយមានជ័យ ដើម្បីទប់ស្កាត់ឈ្មោះ ឡុង ឆេងម៉េង ធ្វើសកម្មភាពឈូសឆាយនៅលើដីរបស់គាត់

• សេចក្តីរាយការណ៍អំពីសកម្មភាពក្រុមជនអនាធិបតេយ្យ ចូលរំលោភបំពានកាន់កាប់ដីរដ្ឋ និងដីមានប័ណ្ណកម្មសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋ ដែលមានទីតាំងស្ថិតនៅចំណុចអូរកំបុត ចំណុចអាងកន្សែង ភូមិទំពសៀម និងចំណុចសំបុកចាប ភូមិបឹងស្នោ ឃុំស្លក្រាម ឃុំស្វាយចេក ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

-រដ្ឋបាលខេត្តតាកែវ ករណីឈ្មោះគន្ធ គា,ឡូត ស្រីពៅ,គាំង ថា,តាំង សៀន,សុំ សុខលី,អៀម នាង, អ៊ូ ប៊ុណ្ណា,ហាក់ ហេង,ថាវ សុគន្ធ,អូន ថា,សែត ខុន និងឈ្មោះដួង សុខាស្នើសុំចេញប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋចំនួន ១២គ្រួសារ ស្ថិតនៅភូមិ២ សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ។

-រដ្ឋបាលខេត្តកំពង់ចាម ករណីស្នើសុំការអនុញ្ញាតសាងសង់អគារសភាពាណិជ្ជកម្មខេត្តកំពង់ចាម និងខេត្តមណ្ឌលគិរី ក្នុងបរិវេណសាលាខេត្តកំពង់ចាមទំហំ ១០ម x ២០ម។

-រដ្ឋបាលខេត្តកំពង់ស្ពឺ ករណីឈ្មោះ ហេង វណ្ណៈ ស្នើសុំប្តឹងឈ្មោះ ម៉ី ខេត ជាមេឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងបក្ខពួកលើករណីប្រើអំណាចឃុបឃិតគ្នាលក់ដីរបស់គាត់ ឱ្យអ្នកផ្សេងស្ថិតនៅភូមិរលួស ឃុំក្រាំង-អំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។

-រដ្ឋបាលខេត្តកែប ករណីធ្វើសេចក្តីរាយការណ៍អំពីកិច្ចការជួយសង្គ្រោះជនរងគ្រោះក្នុងឧបទ្ទវហេតុរលំបាក់អគារ ៦ជាន់ ស្ថិតនៅភូមិកែប សង្កាត់កែប ក្រុងកែប ខេត្តកែប។

-រដ្ឋបាលខេត្តត្បូងឃ្មុំ ករណីតំណាងប្រជាពលរដ្ឋ ២៦១គ្រួសារ ស្នើសុំជួយអន្តរាគមន៍ដកហូតដីព្រៃសហគមន៍ពីអ្នកមានអំណាច និងក្រុមហ៊ុនហាមីនីវីសអ៊ីនវេសមេន ប្រគល់ជូនសហគមន៍វិញ ស្ថិតនៅឃុំត្រពាំងព្រីង ស្រុកតំបែរ ខេត្តត្បូងឃ្មុំ។

-ត្រៀមរៀបចំសម្របសម្រួលសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងលើកទិសដៅការងារឆ្នាំ ២០២០ របស់រដ្ឋបាលរាជធានី ខេត្ត។

-បន្តរៀបចំរបាយការណ៍បូកសរុបលទ្ធផល ការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃកិច្ចការរដ្ឋបាល រាជធានី ខេត្ត ក្នុងការិយបរិច្ឆេទ២០១៩។

**៤.២-ការងារបង្កើត កែសម្រួល និងកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តបន្ទាយមានជ័យស្នើសុំបង្កើតភូមិថ្មីចំនួន០២ ស្ថិតក្នុងឃុំណាំតៅ ស្រុកភ្នំស្រុក និងភូមិចំនួន ០៥ ស្ថិតក្នុងឃុំបិតត្រាំង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ

-បន្តពិនិត្យ និងលើកយោបល់ករណីរដ្ឋបាលខេត្តតាកែវស្នើសុំបំបែកភូមិចំនួន ០៣ ស្ថិតក្នុងឃុំកំពង់រាប និងឃុំព្រៃល្វា ស្រុកព្រៃកប្បាស ខេត្តតាកែវ

-បន្តពិនិត្យ និងលើកយោបល់ ករណីគណៈកម្មការទី១នៃព្រឹទ្ធសភា ស្នើសុំអន្តរាគមន៍ពន្លឿនការសុំបំបែកភូមិ៤ ស្ថិតក្នុងសង្កាត់ដងទង់ ជាពីរ និងការកំណត់ព្រំប្រទល់រដ្ឋបាលរវាងក្រុងខេមរភូមិន្ទ និងស្រុកមណ្ឌលសីមា ដែលស្នើសុំដោយរដ្ឋបាលខេត្តកោះកុង។

-បន្តពិនិត្យ និងលើកយោបល់ ករណីរដ្ឋបាលខេត្តព្រៃវែងស្នើសុំបំបែកភូមិចំនួន៤ ស្ថិតនៅក្នុងឃុំកំពង់ពពិល និងឃុំកញ្ចំ ស្រុកពារាំង ខេត្តព្រៃវែង។

-បន្តពិនិត្យ និងលើកយោបល់ករណីរដ្ឋបាលខេត្តកំពតស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋបាលរវាងក្រុងកំពត និងស្រុកទឹកឈូ។

-បន្តពិនិត្យ និងលើកយោបល់ ករណីស្នើសុំកែសម្រួលព្រំប្រទល់រដ្ឋបាល រវាងខេត្តសៀមរាបជាមួយខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ និងខេត្តបាត់ដំបង។

**៤.៣-ការងារផ្តល់គោរមងារ គ្រឿងឥស្សរិយយស និងមេដាយស្ថាបនាជាតិ**

-បន្តតាមដាន ត្រួតពិនិត្យអំពីការអនុវត្តលិខិតលេខ ១៩៧៣ស.ជ.ណ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការពង្រឹងការគ្រប់គ្រង ការស្នើសុំគ្រឿងឥស្សរិយយសស្ថាបនាជាតិ និងគោរមងារជាឧកញ៉ាជូនសប្បុរសជនដែលមានស្នាដៃ និងគុណបំណាច់ក្នុងការជួយកសាងជាតិក្នុងព្រះរាជាណាចក្រកម្ពុជា។

-បន្តពិនិត្យ និងលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួង ករណីសំណើសុំគ្រឿងឥស្សរិយយសរបស់រដ្ឋបាលខេត្តបាត់ដំបង ស្វាយរៀង កំពង់ចាម បន្ទាយមានជ័យ និងខេត្តព្រៃវែង។

**៤.៤-ការងារសម្របសម្រួល និងសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ និងគម្រោងនានា**

**៤.៤.១-កម្មវិធីគាំទ្រដោយអង្គការ UNICEF**

-បន្តរៀបចំសេចក្តីព្រាងសៀវភៅណែនាំ ស្តីពីកម្មវិធីពានរង្វាន់សម្រាប់ការអនុវត្តសេវាសង្គម នៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

-បន្តចុះតាមដានការអនុវត្តសកម្មភាពសេវាសង្គមនៅរាជធានី ខេត្តគោលដៅ

-បន្តប្រជុំជាមួយតំណាងអង្គការយូនីសេហ្វស្តីពីផែនការសកម្មភាព និងថវិកាឆ្នាំ២០២០។

-បន្តរៀបចំសេចក្តីព្រាង ស្តីពីសៀវភៅណែនាំស្តីពីកម្មវិធីពានរង្វាន់សម្រាប់ការអនុវត្តសេវាសង្គម នៅរដ្ឋបាលថ្នាក់ក្រោមជាតិ ។

**៤.៤.២-គម្រោងសាងសង់អគាររដ្ឋបាល អាគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់ DCOCP**

-ពិនិត្យ និងវាយតម្លៃកញ្ចប់លទ្ធកម្មទី១១នៃគម្រោង

-បន្តតាមដាន និងសម្របសម្រួលទាក់ទងនឹងសំណើសុំថវិកាបន្ថែមទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីរក្សាការសាងសង់អគាររដ្ឋបាល អគារសាលប្រជុំសាលាស្រុក និងអគាររដ្ឋបាលឃុំ សង្កាត់តាមចំនួនដែលបានគ្រោងទុក

-បន្តចុះពិនិត្យ និងតាមដានដំណើរការសាងសង់អគារសាលាស្រុក និងឃុំ សង្កាត់ដំណាក់កាលទី១ និងទី២។

**៤.៥-ការងាររដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់**

-បន្តតាមដាន ត្រួតពិនិត្យការរៀបចំ និងការអនុវត្តថវិកាក្រុង ស្រុក ឃុំ សង្កាត់

-បន្តធ្វើបច្ចុប្បន្នភាពដំណើរការកសាងកម្មវិធីវិនិយោគក្រុង ស្រុក ឃុំ សង្កាត់ឆ្នាំ២០១៩-២០២១ និងឆ្នាំ២០២០-២០២២

-បន្តប្រមូល និងរក្សាទុកទិន្នន័យនៃការអនុវត្តគម្រោង ក្រុង ស្រុក ឃុំ សង្កាត់

-បន្តទំនាក់ទំនងជាមួយរដ្ឋបាលរាជធានី ខេត្ត ដើម្បីជំរុញដំណើរការរៀបចំ និងអនុវត្តគម្រោងក្រុង ស្រុក ឃុំ សង្កាត់

-ត្រៀមរៀបចំកិច្ចប្រជុំស្តីពីស្ថានភាពនៃការគាំទ្ររបស់រដ្ឋបាលរាជធានី ខេត្តដល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ក្នុងការអនុវត្តគម្រោងមូលនិធិក្រុង ស្រុក ឃុំ សង្កាត់ លើកទី៣

-រៀបចំ និងចុះគាំទ្រវគ្គបណ្តុះបណ្តាលសៀវភៅណែនាំស្តីពីការគ្រប់គ្រងមត្តេយ្យសិក្សាសហគមន៍សម្រាប់ឃុំ សង្កាត់ នៅខេត្តកំពង់ធំ ខេត្តកំពង់ស្ពឺ និងខេត្តកំពង់ឆ្នាំង។

-រៀបចំវគ្គបណ្តុះបណ្តាលជំនាញបង្វឹកដល់រដ្ឋបាលខេត្ត ស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ និងការរៀបចំថវិកាឃុំ សង្កាត់។

**៤.៦-ការផ្តល់សេវានៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

-សម្របសម្រួលជាមួយរដ្ឋបាលរាជធានីភ្នំពេញ ក្នុងការរៀបចំដីកា ស្តីពីការធ្វើប្រតិភូកម្មមុខងារពីរដ្ឋបាលរាជធានីទៅរដ្ឋបាលខណ្ឌនីមួយៗ នៃរាជធានីភ្នំពេញ

-បន្តសហការជាមួយលេខាធិការដ្ឋាន គ.ជ.អ.ប និងក្រសួងសុខាភិបាល ក្នុងការរៀបចំ និងដាក់ចេញប្រកាសអន្តរក្រសួង ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមន្ទីរសុខាភិបាលរាជធានី ខេត្ត

-បន្តសហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធផ្សេងៗ និងលេខាធិការដ្ឋានគ.ជ.អ.បក្នុងដំណើរការរៀបចំផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តសហការជាមួយធនាគារពិភពលោក និងក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការកំណត់ក្រុងស្រុកអាទិភាពសម្រាប់អនុវត្តគម្រោងសាកល្បងការគ្រប់គ្រងសំរាមសំណល់រឹង និងសំណល់ប្លាស្ទិក។

-រៀបចំវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសនៃការផ្តល់សេវារដ្ឋបាលតាមវិស័យជំនាញនីមួយៗដែលធ្វើប្រតិភូកម្មដល់ការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌគោលដៅថ្មី

-ត្រៀមរៀបចំប្រជុំពិភាក្សា ជាមួយក្រសួងសាធារណការនិងដឹកជញ្ជូន អំពីការកែសម្រួលប្រព័ន្ធចុះបញ្ជី និងការផ្ទេរប្រព័ន្ធទៅរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីអនុវត្តសម្រាប់ក្រុង ស្រុក៣១គោលដៅឆ្នាំ២០១៨

-ត្រៀមរៀបចំសិក្ខាសាលាបូកសរុបលទ្ធផលការងារឆ្នាំ២០១៩ និងទិសដៅសកម្មភាពការងារឆ្នាំ២០២០ នៃការអនុវត្តការងារច្រកចេញចូលតែមួយ និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

-ត្រៀមរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងទិន្នន័(MIS) ដល់មន្ត្រី នៃការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌគោលដៅថ្មី

-ត្រៀមរៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការផ្តល់សេវានៅអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត

-សហការជាមួយក្រុមហ៊ុន លីហ្សូរ ផេប្រូ ដាក់ឱ្យអនុវត្តសាកល្បងប្រព័ន្ធទូទាត់ថ្លៃសេវារបស់ក្រុមហ៊ុនលីហ្សូរនៅការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌចំនួន០៤គោលដៅ

-ត្រៀមបណ្តុះបណ្តាលប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ៣២គោលដៅថ្មីឆ្នាំ២០១៩ស្តីពីបែបបទ នីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

-តាមដាន ត្រួតពិនិត្យ និងគាំទ្រដល់ការផ្តល់សេវាតាមរយៈយន្តការច្រកចេញចូលតែមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

-គាំទ្រការអនុវត្តតួនាទី ភារកិច្ចការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-ផ្សព្វផ្សាយស្តីពីតួនាទី ភារកិច្ច សមត្ថកិច្ចរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដល់ក្រុមប្រឹក្សា គណៈអភិបាល និងអ្នកពាក់ព័ន្ធ

-រៀបចំសិក្ខាសាលាឆ្លុះបញ្ចាំងប្រចាំឆ្នាំរបស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត

-ពង្រឹងប្រព័ន្ធរបាយការណ៍របស់ការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌផ្សព្វផ្សាយស៊ីជម្របៀបរបបធ្វើការងាររបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ កែលម្អប្រព័ន្ធកត់ត្រាបណ្តឹង និងកែសម្រួលប្រព័ន្ធMIS។

**៥-ការងារសហការជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានា**

ដើម្បីលើកកម្ពស់កិច្ចសហការជាមួយក្រសួង ស្ថាប័ននានា អគ្គនាយកដ្ឋានរដ្ឋបាលបន្តពិនិត្យ និងលើកយោបល់លើករណីដូចខាងក្រោម៖

- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្នើសុំរបាយការណ៍ស្តីពីវឌ្ឍនភាពសម្រាប់ឆ្នាំ២០១៩ នៃការអនុវត្តផែនការសកម្មភាពគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥

- វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ស្នើសុំអញ្ជើញអភិបាលរាជធានី ខេត្តចូលរួមក្នុងសន្និសីទចក្ខុវិស័យកម្ពុជាឆ្នាំ២០២០ ក្រោមប្រធានបទ "កិច្ចសហការក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទីក្រុងឆ្លាតនាពេលអនាគត"។

**៦-ការងារតាមវិស័យផ្សេងៗ**

**៦.១-ការងារគ្រប់គ្រងច្រកទ្វារព្រំដែន និងប័ណ្ណព្រំដែន**

-ត្រៀមរៀបចំកិច្ចប្រជុំលើកទី២ របស់ក្រុមការងារចម្រុះស្តីពីច្រកទ្វារព្រំដែនគោកកម្ពុជា-វៀតណាម

-បន្តធ្វើការបូកសរុប និងសិក្សាលើកយោបល់ពាក់ព័ន្ធនឹងសកម្មភាពទូទៅរបស់ទីស្នាក់ការត្រួតពិនិត្យច្រកទ្វារព្រំដែនក្នុងបណ្តាខេត្តជាប់ព្រំដែនជាមួយប្រទេសជិតខាង

-បន្តសម្របសម្រួលរៀបចំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួងដើម្បីសិក្សា និងដោះស្រាយបញ្ហាបាក់ច្រាំងទន្លេបាសាក់-ទន្លេហ៊ូវ និងព្រែកជ្រៃធំ-ព្រែកប៊ិញយី នៅតាមបណ្តោយព្រំដែនកម្ពុជា-វៀតណាម។

-បន្តតាមដាន និងគាំទ្រដល់រដ្ឋបាលខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវ ដល់ដំណើរការណ៍ផ្តល់ប័ណ្ណព្រំដែន ជូនប្រជាពលរដ្ឋខ្មែរនៅតាមបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវប្រើប្រាស់ ព្រមទាំងបន្តតាមដាន និងសិក្សាលទ្ធភាពក្នុងការផ្តល់សេវាប័ណ្ណព្រំដែននៅក្រុង ស្រុក និងច្រកនៃបណ្តាខេត្តជាប់ព្រំដែនថៃ និងខេត្តជាប់ព្រំដែនឡាវ។

-បន្តតាមដាន និងសិក្សាលទ្ធភាពក្នុងការអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងទិន្នន័យប័ណ្ណព្រំដែនកម្ពុជា/ថៃឱ្យមានភាពប្រសើរឡើង។

**៦.២-ការងារចងសម្ព័ន្ធមេត្រីភាពនិងកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

-បន្តពិនិត្យ និងលើកយោបល់ករណីរដ្ឋបាលខេត្តកោះកុង ស្នើសុំចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការបង្កើតចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងខេត្តកោះកុង ជាមួយខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន។

-បន្តពិនិត្យ និងលើកយោបល់ករណីក្រុងសេជុង នៃសាធារណរដ្ឋកូរ៉េ មានបំណងបង្កើតចំណងសម្ព័ន្ធភាពជាមួយរាជធានី ខេត្តណាមួយនៃព្រះរាជាណាចក្រកម្ពុជា។

-ត្រៀមជូនដំណឹងនិងណែនាំកិច្ចការងារចាំបាច់មួយចំនួនដល់រដ្ឋបាលខេត្តកំពត ករណីភាគីវៀតណាមស្នើសុំជួសជុលកែលម្អផ្លូវសងខាងជាប់បង្គោលព្រំដែនលេខ១៣ ស្ថិតនៅក្នុងតំបន់ច្រកទ្វារព្រំដែនអន្តរជាតិ ហាទៀង (គៀនយ៉ាង)-ព្រែកចាក(កំពត)។

-បន្តពិនិត្យ និងលើកយោបល់ លើសំណើរបស់រដ្ឋបាលខេត្តព្រះសីហនុ ករណីស្នើសុំគោលការណ៍អនុញ្ញាតដឹកនាំគណៈប្រតិភូទៅបំពេញទស្សនកិច្ចសិក្សាអំពីការគ្រប់គ្រងសំណល់រឹង នៅចក្រភពអង់គ្លេស។

-បន្តពិនិត្យ និងលើកយោបល់ លើសំណើរបស់រដ្ឋបាលខេត្តសៀមរាប ករណី៖

- ក្រុងសៀមរាបចងសម្ព័ន្ធមេត្រីភាពជាមួយក្រុងស៊ីអាន ខេត្តសានស៊ី និងក្រុងតាលី ខេត្តយូណាន នៃសាធារណរដ្ឋប្រជាមានិតចិន
- ក្រុមហ៊ុន NIPPON KOEI របស់ប្រទេសជប៉ុនបានធ្វើបទបង្ហាញអំពីគម្រោងសេវាកម្មចល័តថ្មី សម្រាប់បម្រើឱ្យវិស័យទេសចរណ៍ក្នុងក្រុងសៀមរាបជូនថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ។

-បន្តសម្របសម្រួលរៀបចំកិច្ចប្រជុំអភិបាលខេត្តជាប់ព្រំដែនកម្ពុជា-ថៃ លើកទី៧ ដែលភាគីថៃទទួលធ្វើជាម្ចាស់ផ្ទះក្នុងឆ្នាំ២០២០។

**៦.៣-ការងារវិនិយោគ អភិវឌ្ឍន៍ និងអន្តរវិស័យ**

អគ្គនាយកដ្ឋានរដ្ឋបាល បន្តពិនិត្យ និងលើកយោបល់ចំពោះសំណើរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម៖

-រដ្ឋបាលខេត្តមណ្ឌលគិរី ករណីស្នើសុំគោលការណ៍រៀបចំតំបន់រដ្ឋបាលស្រុកអូររាំងថ្មី ដោយកាត់ដីទំហំ ២១៧,៨៣២ហិកតា ស្ថិតនៅក្នុងភូមិពូរ៉ាង ឃុំសែនមនោរម្យ ស្រុកអូររាំង ខេត្តមណ្ឌលគិរី។

-រដ្ឋបាលខេត្តស្ទឹងត្រែង ករណីស្នើសុំគោលការណ៍ដោះស្រាយការតាំងទីលំនៅផ្ទះសម្បែងរបស់ប្រជាពលរដ្ឋរស់នៅលើដីចំណីទន្លេក្នុងក្រុងស្ទឹងត្រែង។

-រដ្ឋបាលខេត្តបាត់ដំបង ករណីស្នើសុំរៀបចំអនុវត្តគម្រោងជីសម្បទានសង្គមកិច្ចសម្រាប់ផ្តល់ជូនប្រជាពលរដ្ឋក្រីក្រដែលរងផលប៉ះពាល់ដោយការបាក់ស្រុតច្រាំងស្ទឹងត្រែងនៅក្នុងស្រុកឯកភ្នំ ខេត្តបាត់ដំបង។

-រដ្ឋបាលខេត្តព្រៃវែង ករណីស្នើសុំជម្រះចេញពីបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលខេត្តព្រៃវែងនូវទីតាំងដីចាក់សំរាម ០១កន្លែង និងយន្តចំនួន ០២គ្រឿង។

-រដ្ឋបាលខេត្តកណ្តាល ករណីស្នើសុំគោលការណ៍ឱ្យក្រុមហ៊ុនដេឌីឌីវេឡុបមេន ឯ.ក បានសាងសង់ច្រាំងទន្លេមេគង្គប្រវែង ១៥គីឡូម៉ែត្រ ស្ថិតក្នុងភូមិសាស្ត្រឃុំឫស្សីជ្រោយ ឃុំព្រែកដំបង ឃុំកោះកោងទី១ ស្រុកមុខកំពូល ខេត្តកណ្តាល និងឃុំស្ពៅ ឃុំកងតាណឹង ស្រុកកងមាស ខេត្តកំពង់ចាម។

-បន្តពិនិត្យ និងលើកយោបល់សំណើសុំផ្តល់អនុលោមភាពគម្រោងអភិវឌ្ឍរបស់រដ្ឋបាលរាជធានី ខេត្ត

-បន្តចុះត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគម្រោងអភិវឌ្ឍឆ្នាំ២០១៩ របស់រដ្ឋបាលរាជធានី ខេត្តក្នុងអំឡុងពេលកំពុងអនុវត្តគម្រោង។

**៦.៤-ការងារកិច្ចការសមាគម និងគណបក្សនយោបាយ**

**៦.៤.១-ការងារកិច្ចការសមាគម និងអង្គការមិនមែនរដ្ឋាភិបាល**

-បន្តលើកយោបល់អំពីការសុំចុះឈ្មោះ សុំបើកទីស្នាក់ការសាខា សុំទទួលស្គាល់ប្រធាន និងសមាសភាពថ្មីនៃបេនាសម្ព័ន្ធ សុំប្តូរទីស្នាក់ការកណ្តាល សុំប្តូរឈ្មោះ សុំធ្វើវិសោធនកម្មលក្ខន្តិកៈ សុំលុបឈ្មោះ ការផ្អាកសកម្មភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងសំណើផ្សេងៗដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ សម្រេច

-បន្តលើកយោបល់អំពីការសុំតម្កល់សំណុំឯកសារ អំពីការផ្លាស់ប្តូរសមាសភាពរចនាសម្ព័ន្ធ និងការធ្វើវិសោធនកម្មលក្ខន្តិកៈរបស់សហគមន៍ជនជាតិដើមភាគតិច

-បន្តអនុវត្តការប្រមូលចំណូលពីកម្រៃសេវារដ្ឋបាល ដើម្បីជាគុណប្រយោជន៍ថវិកាជាតិ

-បន្តគាំទ្រកិច្ចដំណើរការរបស់សមាគមក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ

-បន្តធ្វើបច្ចុប្បន្នភាព និងបូកសរុបរបាយការណ៍សកម្មភាព និងការផ្តល់លេខគណនីរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តតាមដាន ប្រមូលព័ត៌មានពីគ្រប់បណ្តាញព័ត៌មានសង្គមពាក់ព័ន្ធនឹងការធ្វើសកម្មភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តពិនិត្យ និងដោះស្រាយពាក្យបណ្តឹង ឬសំណើនានារបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-ត្រៀមរៀបចំវេទិកា ស្តីពីភាពជាដៃគូរវាងរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលលើកទី៤

-បន្តតាមដានត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលក្ខន្តិកៈរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល

-បន្តរៀបចំកិច្ចប្រជុំពិនិត្យ និងពិគ្រោះយោបល់ជាមួយតំណាងអង្គការសង្គមស៊ីវិលពាក់ព័ន្ធនឹងសំណើសុំធ្វើវិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលលើកទី៤។

**៦.៤.២-ការិយាល័យគណបក្សនយោបាយ**

-បន្តពិនិត្យ លើកយោបល់ អំពីការសុំបង្កើត ឬការសុំចុះបញ្ជីនិងសំណើនានារបស់គណបក្សនយោបាយ ដើម្បីដាក់ជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសម្រេច

-បន្តពិនិត្យ លើកយោបល់ នូវរាល់សំណើពាក់ព័ន្ធនិងការផ្លាស់ប្តូរ ឬការប្រែប្រួលនានារបស់គណបក្សនយោបាយ

-រៀបចំធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះគណបក្សនយោបាយដែលបានបង្កើត បានចុះបញ្ជី និងត្រូវបានលុបឈ្មោះ

-បន្តត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងលក្ខន្តិកៈ របស់គណបក្សនយោបាយ

-បន្តតាមដានពិនិត្យបូកសរុបប្រមូលព័ត៌មានពីគ្រប់បណ្តាញព័ត៌មានសង្គម និងរបាយការណ៍របស់រដ្ឋបាលរាជធានីខេត្តចំពោះគណបក្សនយោបាយដែលបានធ្វើសកម្មភាពផ្ទុយពីលក្ខន្តិកៈច្បាប់ ស្តីពីគណបក្សនយោបាយ និងលិខិតបទដ្ឋានគតិយុត្តជាធរមាននានា

-ពិនិត្យ និងដោះស្រាយពាក្យបណ្តឹង ឬសំណើនានា របស់គណបក្សនយោបាយ។

**អគ្គនាយក**

**ប្រាក់ សំអឿន**

*__ចម្លងជូន៖__*

*-ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ*
*(ជូនជ្រាបជាសេចក្តីរាយការណ៍)*
*-អគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ*
*-អគ្គស្នងការដ្ឋាននគរបាលជាតិ*
*-អគ្គនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ*
*-អគ្គាធិការដ្ឋាន*
*-អគ្គនាយកដ្ឋានពន្ធនាគារ*
*-គ្រប់នាយកដ្ឋានចំណុះអ.រ.ប*
*"ដើម្បីជូនជ្រាប"*
*-ឯកសារ-កាលប្បវត្តិ*